# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ


| | | |
|---|---|---|
| . . . . . . . . . . | បុរាណសុភាសិត . . . . . . . . . . | ៣៩៣ |
| លោក ហេង-ឃាន់ | កំពូលស្នេហា (តមក) . . . . . . . . . | ៣៩៦ |
| ឃុន សុន្ទរមេធី ញូង-សៀង | ឯកសហស្សរាត្រី ភាគទី១១ (តមកនិងចប់) | ៤១៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ព្រះរាជប្រវត្តិ ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា (ព្រះអង្គសួរ) (តមក) . . . . . . . . | ៤២៣ |


*ផ្នែកសាសនា*


| | | |
|---|---|---|
| ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ | ធម្មវិភាវិនី . . . . . . . . . . . . . . | ៤៣៣ |


ឆ្នាំទី ១៨ — លេខ ៨ ខែអ៊ូត ១៩៤៦ — ជំនៀជាវៈ ១ ឆ្នាំ ៣៥ រៀល ។

# ឫកពាសុភាសិត

វិស័យបុត្តល្អនឹងគ្រួន
មើលក្បួនលំអានឫកពាប្រាម
តាខុសពោលទៅតាត្រូវតាម
ឯតាមគួរគោរលក្ខះ ៗ
កុំទៅបណ្ដោយឲ្យរាំងេះ
ព្រែកផ្ទាល់បំណោះលក់មិនឈ្នះ
ទីងបង់របស់អស់តបះ
ភាន់មានៈគន់មនុស្សគេទាំង ៗ
គិតគូឲ្យវែងកុំបែងខ្វី
វិស័យបុនស្រីមើលឫកពា
ផ្គាប់ស្ដេចគោងមើលព្រះទ័យយា
ផ្គាប់ក្រស្ដីប្ដីគាគោងមើលចិត្ត ៗ
ភ្ញៀវមកគោងមើលអាការបេញ
ពោលពាក្យម្ដេចមិញគន់ឃើញពិត
ពាក្យស្ទើរវែងស្លូតជួនជាមិត្រ
ពាក្យពិតជួនពាលមកលវិញ ៗ
ពាក្យលេងជួនខ្សែតលប្រាញ
ពាក្យព្រាងមុសាគាគេជេញ
អ្នកខ្វនគោងឃាតពីទៅបេញ
ស្រទ្បាញ់គោងបមលោមមើលចិត្ត ៗ
គេលើកកុំឡើងទៅតាមយស
ឡើងខ្ពស់មើលតាបក្រោមមិត្រ
ដើរមុខខុតក្រោយកុំឲ្យជិត
លោភៃប្រគោងប្រព្រឹត្តកុំប្រែ ៗ
ភាន់ប្រាជ្ញកុំប្រែបស្រមែបកាម
ហួសហើយកុំហាមឲ្យកាមកែ
បម្ងែគោងវៀរវៀសវែរ
វៀនស្នេហ៍គោងស៊ូខចិត្តឲ្យស្ងួន ៗ
ប្រាក់មានលើកឲ្យគេខ្ចីទៅ
បំណោះបេះនៅតែកនិកក្បួន
បែពន្ធនៅឆ្ងាយអំពីខ្លួន
ផល់ជួនត្រូវការរក៏បិត្ត ៗ
បេះប្រែនលំបាកយាយ៉ាទីងគេប
បេះតិបព្រួយប្រាណាំរាន់គិត
លួងលើប្រើការជួបងនឹក
ឥតបើគិតមិនកើតការនោះបាន ៗ

តាំងខ្លួនគោងឃ្លាតពីទៅចេញ វង្វេងណាស់លសោញហួសប្រមាណ
លក់ម្ជុលមើលដើមឲ្យដឹងជាន គិតអានសុំធ្វើតាមប្រាជ្ញ ។
ខ្ជួតលៀនផ្ទះលុបអុំឲ្យល្អិត ក្បួនគេប្រើតែម្តងគង់ប្រែះជា
ទំលោះប្រយ័ត្នចេញកោង គិតកាប់ឯណាកុំកាន់ជិត ។
ក្តាក់មាត់មិនទប់កំពប់ប្រាក់ ក្តាក់ជើង ១ បាក់មាន់ថ្នាំបិទ
ក្តាក់ការគន់កែបំបែរគិត ក្តាក់ចិត្តគង់បាប់ទៅតាមបេះ ។
បេលើញ្ញាតិឃ្លាតប្រាប់បាប់វេក យល់ការគន់ឃ្លាតយៀនចំណេះ
ដំរីជើងបួនគង់ភ្លាត់ភេះ អ្នកប្រាជ្ញដែលបេះគង់ភ្លាត់ខ្លះ ។
ចាប់ត្រីដៃពីរគេស្រាំហាម ចាប់អង្គរយេតអង្គាមហាមមិនឈ្នះ
កុំខ្វះទៀនក្លួនមានៈ បងព្រះទៅសំពះឯបាយាប ។
ស្មៀតសសានព្រឹតចិត្តនៅទៅ ពោលប្រាជ្ញតាមទៅបង់ទៀសបាប
ល្អូកវែកឲ្យដឹងសៅប្រែសាប យកទ្រាប់មកតាបបានប្រែងថ្លៃ ។
ប្តូរស្បៀធ្វើក្តាត់ដាក់គ្មានថ្នាំង គងស្តូវគាំងរាយមិនត្រូ
សុរិយាមិនយកជាពន្លឺ យប់ដៀអំពិលអំពែកសត្វ ។
បងអ្វីមិនខ្លាប់ស្មើសង្សារ ការអ្វីមិនស្មើការប្រតិបត្តិ
ស្លាកអ្វីមិនស្មើចិត្តដែលស្លាក កាចអ្វីមិនស្មើជនពាលា ។
ពេកអ្វីមិនស្មើនឹងពេកឃ្លាន ខានអ្វីមិនស្មើខានទេសនា
មានអ្វីមិនស្មើមានប្រាជ្ញា ជាអ្វីមិនស្មើចិត្តជាបុណ្យ ។
រហ័សអ្វីមិនស្មើចិត្តដែលនឹក មុតអ្វីមិនស្មើទឹកហូរជោរជន់

ប្អូនអ្នកមិនស្មើព្រះគុណប្អូន ផងអ្នកមិនស្មើម្រឹគនេត្រ ។
មើលមេឃគោងមើលទៅទេវតា ចូលព្រៃព្រឹក្សាគោងមើលលើ
យកម៉ែត្រមើលចិត្តឲ្យស្មោះស្មើ យកភ្នែកគោងមើលឲ្យសមប្រាណ ។
ធ្វើស្រែចំការឲ្យមើលស្មៅ ទុកដាក់កូនចៅមើលសន្តាន
ធ្វើទីលំនៅមើលភូមិឋាន បរិភោគប្រមាណមើលអាហារ ។
ដាំមុក ៗ មែននៅក្នុងស្រោម វិជ្ជាបេះព្រមមិនគួរឆារ
ដាក់ស្រែកក្តួចទឹងព្យាបាល តផ្សារកេកហ្វូទឹងប្រផេះ ។
ទិចខ្លាចគេឥតទុចដំកល់ ដាក់ដែក ៗ ដុលខ្លាចជំពេរ
ត្រញងខ្លាចធ្វើខុបកួបដុបស្មៅ ទុកខ្លាចគេទៅដាំងនៃមផ្ទៀង ។
បោកប្រយ័ត្នមាត់អំបិល ដាំងទឹងការ់សិលប្រយ័ត្នទៀង
ទៅក្រមប្រយ័ត្នមិនលំអៀង អ្នកផ្ទៀងប្រយ័ត្នបាត់អន្ទាក់ ។
លលេងកូនក្មេងអង់កាប់ឃោស លលេងទឹងពស់អង់បំផ្លា
លលេងអ្វី ៗ គង់គេថា លេងស្រីលេងស្រាអង់ធ្លាក់បក្ខ ។
ឯស្រាទឹងស្រីបីងល្បែង គួរលះគួរលែងកុំប្រព្រឹត្ត
ព្រោះនាំឲ្យខូចអំពល់ចិត្ត វិបរិតផ្តាសៗ ក្នុងលោកិយ ។
តែថាឯស្រាទឹងការល្បែង គួរលះគួរលែងបានមិនអ្វី
ឯត្រង់បំណាច់បង់ទឹងស្ត្រី លោកិយឃើញក្រលះបាន ។
លះបាននៃលោកព្រះយោគា ការនាំកើនព្រះធម្មជាន
បន្ទុយក្តីស្រេកសម្រេចឃ្មាន កាំងនៅក្នុងឈានស្ងប់ស្ងាត់អើយ ។

# កំពូលស្នេហា

## លោកហេង-យ៉ាន់ រៀបរៀង

(តមក)

### វគ្គទី ៩

### បងឆ្អែតចិត្តហើយអូន!

ការស្នេហារបស់លោកគ្រូនិងបុត្រីថៃខ្លួនសូស្រស់កាន់តែជិតជិតឡើង ណាស់ហើយ អ្នកទាំងពីរក៏មានទឹកចិត្តស្រឡាញ់គ្នាទៅវិញទៅមក តែងសេះសេងគ្នាដោយពាក្យផ្អែមពីរោះ ហើយដាក់ជូនចិត្តគ្នាមិនឲ្យមានខ្លាង ដោយហេតុនាំឲ្យស្នេហ៍ពន្ធៈនេះពេលកាលកាន់តែខ្លាំងឡើង, បំណែកតាសុខុំ ណាមួយឲ្យអ្នកទាំងពីរប្រតិបត្តិតាមគន្លងប្រពៃណី ដោយសេចក្ដីទុកចិត្ត ហើយតែងញញឹមពេញចិត្តដល់កលមាយាក្រមុំកំឡោះទាំងពីរនោះ ញាតិសន្ដានក៏បានគិតកំណត់ថ្ងៃមង្គលរៀបការពារហ៍ពិពាហ៍ក្នុងខែកត្តិក នាឆ្នាំនេះឯង ។

ថ្ងៃ ១ ជាល្ងាចថ្ងៃសៅរ៍ខែពិសាខ លោកគ្រូទេពភក្ដីបង់នាំដំណឹងល្អនោះ ក៏នៅផ្សាយប្រាប់អាចារ្យដែលអ្នកមានគុណបទាតះលើខ្លួនឲ្យបានដឹងផង ទើបផ្លាស់ខោអាវចុះចេញពីផ្ទះ ដើរផ្ទែមមកសំណាក់អាចារ្យ គ្រួអាចារ្យនៅក្នុងបន្ទប់ទទួលភ្ញៀវកំពុងសរសេរ ដល់ឃើញភ្ញៀវមក អាចារ្យក៏ចោលការសរសេរមកធ្វើបដិសណ្ឋារៈរាក់ទាក់ លុះអង្គុយលេង

ពិសាខាលើកោះអ៊ីផលីម៉ោងបួនកន្លះ  អ្នកទាំងពីរក៏ព្រាត់គ្នានឹងទៅអគ្គិយ លេងនៅកោះអីវគ្គក្ដី  ទើបនាំគ្នាកែសងតាមផ្លូវប៊ូលវ៉ាក៏ទៅ, លុះដល់ផ្ទះពីរជាន់មានរបងដែកខាងមុខក្រហមព្រែងពីលើ  សោភ័ក្ត្រក៏ហៅណាត្យឲ្យមើលទៅចិញ្ចើមថ្នល់ម្ខាង ។

នៅលើចិញ្ចើមថ្នល់នោះ  មាននារីម្នាក់រូបឆោមឆើតឆាយស្លៀកសំពត់ខៀវពាក់អាវខ្នាប់សាប៊ែប "ស៊ីមីស" ដៃឆ្វេងយួរក្រប៉ៅស្បែក មានប្អូនស្រីដើរតាមក្រោយផង ទំនងទើបនឹងចេញពីសាលារៀន សោ-ភ័ក្ត្រឃើញដូច្នោះ ក៏ទន្ទឹងចិត្តមួយសន្ទុះហើយបាត់ស្លាក់ទៅ ព្រោះនាងនោះគឺណារ៉ាដនេត្រនារី នាងបានបោលកន្ទុយភ្នែកមើលមក ធ្វើមុខមាំមាត់ស្ងួត ៗ អើតាមផ្លូវទៅ ។

"អាចារ្យស្គាល់ទេអ្នកនោះ?"

"ទេ ខ្ញុំជួបជាបន្ទោះ" ។

"នេះបានចំជាស្អាតមែន  មិនស្គាល់ពិតឬ?"

ថាហើយសោភ័ក្ត្រក៏សើច  នឹកក្នុងចិត្តថា  អាចារ្យនេះឆ្កួតមួយគំណាក់ខ្លួនហើយគេ បេះដៃដើរមិនមើលអ្វី ដូចជាគ្មានវិញ្ញាណ សព្វថ្ងៃសិស្សរបស់ឯងក៏មិនស្គាល់ដែរ យ៉ាងនេះបញ្ជាក់ជាច្បាស់ប្រាកដខួរគេប្រពន្ធឯងមិនវែងឡើយ កន្សែងនឹងជាពេកមិនមែនដែរ ព្រោះគាត់ធ្លាប់តែក្មេងដូច្នេះ ហើយក៏ស្ងៀមដើរតទៅទៀត ។

លុះដល់វត្តភិរម្យតាំងពីតើតគន្ធ័យលេងលើគោកអ៊ី បញ្ចូនការម្ហណ៍ ឲ្យរកតាមដំណើរបេក្សាបក្ស ដែលហិបហើរពីទីនេះទៅទីនោះព្រមទាំង សត្វស្លាបរៀងរៀងខ្លួនៗ ល្ងូងល្ងើយ សមខ្យល់រំភើយផាត់ស្ទើតល្ហើឲ្យ ជ្រះថាកទង់ម្តងមួយ គួរឲ្យជ្រួបក្លួចទឹកស្រមៃដល់គួត្រង់ ពួងពេលនោះ កាពបុត្រថ្មីខ្សែល្អស ក៏ប្រាកដដល់ចិត្តសោកក្រៃដែលទំនុសទាំងអគ្គ កាយមួយរំពេចក្បួនទឹកដល់អាចារ្យដែលឆ្ងាយបៀតខ្លួន ប្រវត្តិដល់ពេល ដែលបានបួបបួនទឹងកៃខ្លួនល្អង ទឹកដល់កំរើផ្កាដែលបានបំពាក់ដៃនាង នឹកដល់ពន្លឺបង្អៀងដែលបំភ្លឺមុខស្រស់កល្យាណ ឲ្យនាងដេរប៉ាក់បាន ដោយស្រួល ចំណែកអាចារ្យក៏រំជួលចិត្តដោយអាគាសព្រោងព្រាយ សប្បាយនោះដែរ ។

មួយសន្ទុះក្រោយមក អាចារ្យក៏បណ្តាលស្បែងខ្វាំង ហូកកូន កន្ត្រៃមកជូនប្រមុះ ឯកូនកន្ត្រៃនោះមានផលសើមជុំវិញជាក្បូរក្បាច់ ពនាយាំងវិប្ញក៏ ធ្វើឲ្យសោកក្រពឹក់ពាក់ចិត្តមើលមិនដាក់ភ្នែក អាចារ្យ ឃើញឈរពិនិត្យដោយយកចិត្តទុកដាក់របស់អ្នកអង្គុយជិតខាងជួរោះ ក៏ និយាយឡើងថា :

" ឯងជួបជាបចិត្តទឹងកូនកន្ត្រៃនេះពេក ឯងដឹងជាស្នាដៃរបស់ នរណាទេ? គឺស្នាដៃរបស់ណុជនេត្រនារី នាងបានឲ្យខ្ញុំកាលពីកាស បុលឆាំថី ខ្ញុំក៏បានយកមកប្រើជាប្រចាំដៃ ព្រោះថ្ងៃណានាងមិន

ឃើញនៅជាប់កូនហោចៅរបស់ខ្ញុំហើយ នាងតែងរអ៊ូមុខក្រញូវមែន ស្រស់កូនថ្លៃនោះ ។

"បើតាមខ្ញុំ យល់ឃើញថា នាងពេញចិត្តនឹងអាចារ្យច្រើនណាស់ សោកក្ដីពោលដោយស្មោះអស់ពីចិត្ត, មួយវិញទៀតរូបនាងក៏សំខាន់សម្បត្តិនាងក៏មាន គួរណាស់តែអាចារ្យដណ្ដឹងយកជាគូគ្រង ឬអាចារ្យគិតឃើញថែបណា ធម្មតាប្រុសកំលោះគោងតែតំកល់ស្រីសារទើបគួរ ព្រោះកាលបើនៅលីវនោះ គ្មានអ្នកមកធ្វើឲ្យជំពាក់ចិត្តបាន ក៏ថែរជាចាយវាយផ្ដេសផ្ដាសអសារឥតការទៅ ចំណែករូបខ្ញុំ ៗ បានគិតផល់រឿងនេះទុកជាស្រេចហើយទើបបាននាំយកដំណើរល្អនេះមកជំរាបអាចារ្យផង គឺខ្ញុំបានទទួលយកបុត្រីថ្លៃល្អសជាប្រពន្ធ ចាំនឹងរៀបអាពាហ៍ពិពាហ៍កូនថ្ងៃចក្ខុក្រោយនេះ ហើយខ្ញុំសូមអង្វរអាចារ្យឲ្យអញ្ជើញទៅជាសិរីសួស្ដីនាថ្ងៃជាមង្គលនោះកុំខាន" ។

អាចារ្យសំដែងសេចក្ដីត្រេកអរ ព្រមទទួលជាភ្ញៀវហើយជាប់បញ្ចប់សេចក្ដីថា:

"ចំណែករូបខ្ញុំ ៗ មិនត្រូវការនឹងលោកិយទេ ខ្ញុំមានបំណងតែមួយ គឺបួលបួសកូនព្រះពុទ្ធសាសនាដើរធុតង្គកម្មល ទ្រព្យសម្បត្តិស្ត្រីសម្បត្តិក៏ពិតមែន ឯណាផលេត្រនារីល្អពិតហើយ តែមិនសមនឹងខ្ញុំទេ មួយវិញទៀតខ្ញុំគ្មានចិត្តជាប់ជំពាក់ផលរូបនាងបន្តិចបន្តួច ខ្ញុំសូមបញ្ជាក់

ប្រាប់សោភ័ក្ត្រឯងថា ខ្ញុំមិនត្រូវការនារីជាគូគ្រងទេ ក្រែងតែចៅណៅ ទៅថ្ងៃមុខដូចម្តេចទៅក៏មិនដឹង ។ បើសោភ័ក្ត្រឯងវិញបានសមចិត្តនាង ឥឡូវបើឯងឥណ្តឹងបុត្រីបវរស្រួលសហួសទៅហើយក៏ជាដែរ" ។

*

* *

ក្រោយនោះមួយអាទិត្យមក សោភ័ក្ត្រឈប់នៅផ្ទះ ពេលនោះត្រជាក់ស្រួលមិនក្តៅដូចធម្មតា គួរឲ្យនឹកចង់យាត្រាកំសាន្តតាមផ្លូវ សោភ័ក្ត្រក៏បន្ធាត់ចិត្តឲ្យរេរើកាយទៅក្នុងអារម្មណ៍ផ្សេងៗ ពោលតែគិតតាម មើលពពកឯវេហាស៍ដែលរសាត់ទៅបន្តគ្នាជារូបភាពផ្សេងៗ ជាសិង្ហ គោ, តោ, ដំរី, មនុស្សស្តឹមស្តៃជិះសេះ ។ ល ។ សោភ័ក្ត្រនឹកព្រួយចង់សោក កាយពពកទៅៗ រករម្មណីយដ្ឋានដែលខ្លួនមិនដែលស្គាល់ ចង់ឲ្យបានយល់ឲ្យបានទៅនៅទីនោះតែម្នាក់ឯង ភ្លើតភ្លើនក្នុងការស្រមៃនោះអស់កាលដ៏យូរ ។

ចុងបំផុតបានពោលក្នុយភ្នែកមៀងមើលហ៊ឹងនៅលើថ្នាក់បង្អួច ឃើញផ្កាកុឡាបមួយក្រៀមស្វិតក្នុងកញ្ចក់ សោភ័ក្ត្រឈោងដៃទាញយកមកមើលឃើញមានចំណងជើងថា "កុឡាបជីវិត" គឺផ្កាដែលពក្រុផនេត្របានឲ្យជាវង្វាន់នៅពេលយប់មួយ ក្នុងពេលនោះ មុខណក្រុផនេត្រលេចភ្លាមឡើងច្បាស់ដល់ភ្នែកសោភ័ក្ត្រ ទើបបុរសនោះអង្គុយចុះមួយសន្ទុះ

ក៏ហាក់ដូចជាមានអ្វីគ្រាក់ឲ្យដឹងខ្លួនឡើង ឲ្យភ្ញាក់ផ្អើមក្តុកញើរដើមទ្រូ
ពកីបមួយស្រេចក់តមកមានអ្វីយ៉ាងស្រាលសន្សើមៗ ដុះចេញពីបេះដូងមក
តាចចេញពីបំពង់កយ៉ាងខ្ទង់ខ្ទប់ ដោយមិនដឹងខ្លួន គាត់សោកក្រៀក
ការពារខ្លួនឈ្មោះជីតាកោះមួយ នេះតើដោយហេតុអ្វី? ហើយឈ្មោះនោះ
តើជាឈ្មោះនរណា? ជាមញ្ញាដែលអ្នកមើលគួរពិចារណា លងមើលដើម្បី
នឹងដឹងច្បាស់ផលជំពៅរចិត្តចិត្តមនុស្សលោក ។

អស់លោកអ្នកប្រហែលជាបានសង្កេតមើល ដុំក្រួសដែលគេ
ទំលាក់ក្នុងទឹកត្រពាំងដែរ បើបានសង្កេតនោះគង់នឹងដឹងសេចក្តីបានថាប៉ះ
ទង្គិចរួចក្រួសនោះបាត់ស្រមោលកន្លងក្នុងទឹកទៅហើយ ផ្ទៃទឹកនៅតែ
កន្ត្រាញ់ជារង្វង់សាត់ទៅខាងនៅឡើយ ក្រោយមកមានពពុះទឹកផុស
ឡើងព្រមទាំងកករដ៏មកផង ដែលនាំឲ្យយើងដឹងថាមានដុំក្រួសធ្លាក់ត្រង់
នោះ រីឯចិត្តមនុស្សយើងក៏ដូចគ្នា អារម្មណ៍ដែលយើងបានក្តួចទុកក្នុង
ចិត្តហើយ ដែលយើងមិនបានជាទុកនា តែងជិតជាប់ក្នុងហឫទ័យមិន
រលុបបង់ តែងគ្រាប់រង្គាត់ក្នុងនោះ ដោយមិនឲ្យយើងដឹងខ្លួន លុះមាន
ឱកាសនឹងស្ទុះចេញមកបានក៏លេចធ្លោឡើង ដែលសំដែងឲ្យឃើញថា
យើងបានផ្តិតផ្តិតនឹងអារម្មណ៍នោះខ្លាំងណាស់ ។

ចុះឈ្មោះជីកបិតកំបាំងនោះជាឈ្មោះនរណាហ្ន៎! បើយើងស្គាល់
អធ្យាស្រ័យសោកក្រៀមស្លុតសំណាស់ខន្ធនឹងដឹងថា គ្មាននរណាក្រៅពី

“ណុផនេត្រនារី” ទេ ។ គឺថាលោកគ្រូជាប់ជំពាក់ចិត្តស្នេហាដល់ស៊ុធី យ៉ាងស្មោះអស់ពីថ្លើម ស៊ូប្តូរជីវិតជាមួយនឹងនាង ស៊ូទុក្ខសោកព្រោះតែនាង នេះហើយជាសេចក្តីស្នេហាដ៏ខ្ជាប់ខ្ជួនឋិតថេរ ហើយក្នុងមួយជីវិតមនុស្សនោះ មានសេចក្តីស្នេហាប្រភេទនេះតែម្តងប៉ុណ្ណោះ ចុះបើលោកគ្រូពេញចិត្តនឹងគាថខ្សែល្អសណាស់ដែរ ហើយនាងនោះមុខជានឹងបានជាភរិយារបស់គេក្នុងពេលមិនយូរប៉ុន្មាន នឹងថាមិនមែនជាសេចក្តីស្នេហាដ៏ស្មោះឬ? ត្រង់នេះមិនគួរឆ្ងល់ឡើយ សេចក្តីស្រឡាញ់ក្នុងក្រោយនេះ មានកំឡាំងត្រឹមតែតណ្ហាប៉ុណ្ណោះ កុំប្រឡំសេចក្តីស្នេហានឹងតណ្ហាឲ្យសោះ ត្រាន់តែមានដំណើរដូចគ្នាប៉ុណ្ណោះ តែមានឋានៈខុសគ្នាឆ្ងាយណាស់ ។

ពេលប៉េណ្ណោះផ្កាទឹស្រឡាញ់កំពុងពុះពោរក្នុងដើមទ្រូងហើយ យកដៃស្ទាបថ្ពាល់ទុកម្នាម្នេញ នាំឲ្យលើកនឹកដល់ណុផនេត្រនារីទេចទល់ពុំឈប់ ។

លុះយកកូនចន្ទៀនមកដូតមុខ ក៏នឹកដល់កូនចន្ទៀនដែលណុផនេត្រនារីបានឲ្យភាពាស្យ ទើបយល់ឃើញថា របស់ខ្លួនមិនល្អ ឯគុណសម្បត្តិរបស់ណុផនេត្រនារីគាប់តែបញ្ចាស់ដល់ចិត្តលោកគ្រូ ពាក្យអាថាស្យមួយម៉ាត់ “ បើលោកគ្រូឯងវិញបានសមនឹងនាង ” ទើបនឹកពេញខ្លួកក្បាល

ដល់ពេលនោះ ៗ ទើបសោភ័ក្ត្រ ផ្លាស់សំពត់អាវចុះចេញដើរតាមផ្លូវទៅ ចួនជាពេលនោះណុជនេត្រពុះពីសាលាមកតែបានប្រទះគ្នា សោភ័ក្ត្រ ឃើញហើយខឹងអស់តាំងខ្លួនប្រាណ មានចិត្តប្រតិព័ទ្ធនឹងនាងរឹងរឹតតែ ខ្លាំងឡើងស្ទើរស្ទុះទៅឱបក្រសោបបី ដើរដល់ផ្លូវបំបែកមួយមានដើមស្វា ដុះជាជួរតាមរបងផ្ទះ សោភ័ក្ត្រទើបកាត់ចិត្តចូលទៅជិតនាង ដោះមួក ហើយសួរដោយសំឡេងញ័រថា

"បាត់មុខយូរដូចជាចំឡែក ទើបនឹងមកពីរៀនឬអ្នក" ៗ

"ចា៎ស មកពីរៀន" នាងតបមកវិញកំបុតជួយមុខមិនស្រស់សោះ" ៗ

"ខ្ញុំបានជាខុសគ្នាទៅហើយពីមុននោះ ខ្ញុំលន់តួថាខុសពិត ខ្ញុំ សូមសួរអោយស្មោះថា តើខឹងនឹងខ្ញុំណាស់ទៅឬអ្នក"

"ឥតខឹងទេ" យាំងគំពេះគំរើយ រួចបែកគ្នាទៅ ៗ

សោភ័ក្ត្រមានចិត្តរីករាយត្រេកត្រអាលជាប្រិន ដើរដញ្ចឹងបួន សំដីរបស់នាងមើលទើបយល់ថា បើជានាងខឹងនឹងអញមែន នោះមុខជា ស្អប់លែងមើលមុខហើយ តែនេះនាងបាននិយាយរក ក៏ឃើញថានៅ ចូលចិត្តសមាគមនឹងអញនៅឡើយ បើដូច្នោះគួរខំប្រឹងប្រែងក្រែង គោជាសមដូចបំណង ៗ ដល់ដូចពេលក្រោយបាននិយាយជាមួយ នាងដោយពាក្យបែបនេះ

"ប្អូន ការដែលខ្ញុំហ៊ានសារសងគេតាមផ្លូវដូច្នេះមិនជាការក្រោធខឹងដល់ប្អូនទេ ឬអ្វី ប្អូនមិនចាប់ទោសបងទេ ឬ?"

"ចា៎ះទេ" ។

"ប្អូន, តាំងពីខ្ញុំបែកពីប្អូនទៅ, ព្រោះប្អូនស្អប់មិនចង់ឃើញមុខខ្ញុំ កើតទុក្ខកើតអ្វីប្រែប្រួលផងពុំបាន គេងក៏ពុំលក់ ញ៉ាំបាយក៏ពុំបាន សូម្បីខ្លួនប្រាណអស់ដូចប្អូនឃើញនឹងភ្នែកស្រាប់ គិតអ្វីក៏មិនកើត រវល់តែនឹងសម្រក់ទឹកភ្នែកកល់ក្រៃ បានប្អូននិយាយរកខ្ញុំវិញ ខ្ញុំមានចិត្តត្រេកអរណាស់ ហាក់ដូចជាខ្ញុំស្លាប់ទៅហើយបានប្អូនមកជួយប្រោះឲ្យរស់ឡើងវិញ ចាប់ពីថ្ងៃនេះទៅ ទុក្ខសោកកង្វល់របស់ខ្ញុំនឹងវិនាសបាត់ទាំងអស់ បាយពុំមាន តែបើព្រួយមិនបាននិយាយលេងជាមួយប្អូន បានឃើញមុខ បានស្តាប់សំដីប្អូន" ។ កងវេលានោះ នាងនៅតែស្ងៀម ទឹកមុខនៅតែដដែល សោភ័ក្រ្តឃើញអាកប្បកិរិយានាងដូច្នោះ ក៏លានាងដើរឈោកមុខចៀសចេញទៅ ។ លុះដល់ព្រឹកថ្ងៃសៅរ៍ជាថ្ងៃត្រូវតាមពេលសន្យា ដល់ក្រស្តបាក់ឌដែលស្ថាប់ដោយត្រាប់តែបប្រទេសអង់គ្លេស សោភ័ក្រ្តក៏ដើរទៅចូលនឹងណុជេនត្រង់ទៀត ។ គួរឲ្យអស្ចារ្យណាស់ព្រឹកនោះ ស្រាប់តែណុជេនត្រូវរញ៉ីញ៉ីមដាក់មុខចុះ សោភ័ក្រ្តឃើញនាងមានអារម្មណ៍ល្អក៏សួរថា

"ម្ដេចក៏មិនចាំផងក្រែ ឲ្យប្អូនចាំផងទៅវិញ មិនក្ដៅទេឬអ្វី?"

"ស្រេចនឹងខ្ញុំ" រួចនាងញញឹមដើរហួសទៅ ។

សោភ័ក្ត្រលាន់មាត់ថា ថ្ងៃនេះនាងញញឹមមករកបងច្បាស់ជាមានចិត្តស្រឡាញ់អញខ្លះមិនលែងទេ បើដូច្នោះគួរអញប្រឹងព្យាយាមលងមើល ដល់ល្ងាច អង្គុយអន្ទះសារចាំពេល គ្មានអ្វីធ្វើចិត្តឲ្យស្ងប់ សល់អន្ទះអន្ទែងផងសេចក្ដីចាំទេ តែបានជាស៊ូទ្រាំរង់ចាំទៅកើត ព្រោះសង្ឃឹមមាំថានឹងសមដូចបំណង សោភ័ក្ត្រត្រាស់ត្រាល់ចុះឡើងពេញផ្ទះ តែងសំឡឹងមើលនាលិកាជាច្រើនដង ឃើញដូចជាទ្រនិចវាលយឺតខុសធម្មតា ស្ទើរនឹងសុះទៅបង្វិលឲ្យដល់ម៉ោងភ្លាម ជួនចិត្តស្មានម៉ោងខុសទើបចុះទៅមើលថ្ងៃៗ នៅតែយឺត ... ចុងបំផុតម៉ោងក៏វាយច្បាស់ៗ ដល់ប្រាំបី ទើបសោភ័ក្ត្ររៀបខ្លួនស្លៀកពាក់ខោអាវសំអាតខ្លួនឲ្យសមជាងមុន រួចដើរចុះទៅចាំមើលផ្លូវនាង ។

មានចិត្តរំភើបចង្ក្រិតម្ដងៗ ជាលំដាប់ ទំរៀងត្រចៀកស្ដាប់ស្នូរស្បែកជើងពីក្រោយខ្នង ចង្កិតត្រើស ៗ នឹកស្មានថា ច្បាស់ជានាងមក ទើបងាកបែរមើលក្រោយភ្លាម ពុំជាអើយ ប្រឡែងសោះ គេដទៃទេ ដល់ឮស្នូរស្បែកជើងទៀតក៏នឹកព្រួចក្នុងចិត្តច្បាស់ជានាងហើយម្ដងនេះ អនិច្ចាអើយ ... ដល់បែរមុខដើរមកក្រោយវិញក៏ពុំឃើញនាង កើតអស់

កំឡាំងលើកជើងមិនរួច ដើរបន្តរជម្រើនទៅផ្លូវអ្នកហៃយេវិញ មុខស្លាំង គួរឲ្យអាណិតណាស់ ដើរងក់ៗ ទៅស្រាប់តែប្រទះនឹងណុជនេត្រនារីក មួន មុខសោភ័ក្ត្រក៏រីកដូចជារះសប្បាយចិត្តណាស់ ប្រហែលគាត់នឹងកូន ដែលបាត់ម្ដាយយូរ ដល់ឃើញអ្នកត្រឡប់វិលមកវិញ ចង់ស្ទុះទៅថើប តាំងពីម្ដាយ ទើបញញឹមញញែមទំដើរឡើងលឿនជាងទៅរកនាង ។

តែសោភ័ក្ត្រគាំងទប់ចិត្ត ដោយណុជនេត្រងាកមុខចេញ ធ្វើព្រងើយដូចជាមិនដឹង ដើរហួសទៅចោលសោភ័ក្ត្រឲ្យនៅនឹងកន្លែង ឲ្យឈរទ្រឹងហាក់ដូចក្លាយទៅជារូបថ្មមួយរំពេច រលួយអស់ថ្លើមប្រមាត់ សពដង្ហើមស្ទើរពុំចេញ ក្ដួលក្ដុកចុចណែនក្នុងទ្រូង ស្ទុះដើរអង្គុយចុះលើចិញ្ចើមថ្នល់ តែភ្នែកនៅតែមើលណុជនេត្រនារីទាល់តែផុតលែងឃើញ ទឹកភ្នែកក៏ហូរចេញមកក្លាយពេញមុខ ពួកក្មេងៗ នាំគ្នាកោមមើលស្ងើចស្ងាន ថាសោភ័ក្ត្រជាមនុស្សឆ្កួត ខ្លះបេះយកដុំក្រួសចោល ខ្លះចង់ឲ្យគេញាក់មុខឲ្យ ពួកចាស់ៗឃើញដូច្នោះគ្រវីក្បាលគិតសង្វេគហើយដើរហួសទៅ ។

ឯសោភ័ក្ត្រខ្សឹកខ្សួលរំជួលថ្លើមអស់ពេលជាយូរ ទើបងើបមុខឡើង ក្រោកដើរគេះគះ ព្រោះទុក្ខធ្ងន់ណាស់យោងអាត្មាស្ទើរពុំរួច ឡើងជិះត្រីចក្រយានវិលទៅផ្ទះវិញ ត្អូញថ្ងូរតែក្នុងចិត្តថា ៖

"ណុជនេត្រពុំគួរធ្វើបងដល់ប៉ុណ្ណោះសោះ បងខ្លោចចិត្តហើយអូន!"

ដល់ផ្ទះហើយ សោភ័ក្ត្រមិនបានបរិភោគអាហារអន្ទើយជាទុក្ខនៅ ពេនខាងមុខ សំឡឹងមើលមេឃដោយ . . . ដោយប្រាសចាកវិញ្ញាណ រហូតដល់យប់ទឹកបានពូលទៅសន្ទឹងលើគ្រែ បើកបង្អួចមៀនមើល កាកគរ ។

ព្រះចន្ទ្រនាងរនោច មានសណ្ឋានដូចទូកតេល់យេបណ្ដាលសមុទ្រ នភាល័យ មានរស្មីស្រទន់ព្រលរ រមិលមើលទៅព្រៃយក្សនានា ឃើញសម្ងៀមមហិមាខ្ពស់ធម្មតា ឯព្រឹក្សាមានស្រមោលខ្មៅស្ទុងបីដូចជា បិសាចលង គួរឲ្យភ័យស្លុតព្រឺព្រួចពន់ពេក បក្សីផងដេកជៀយស្ងាត់ ឈឹងស្ងប់ ។ នៅវេលានោះគេគាបទឹងស្ដាប់នូវសូរសន្ធឹកឈាមរកសព្វ សារសែសរួបធំ ។ សត្វវរនិលបន្លឺគក់ចាត់ពុំព្រៀបដូចសព្វផង យូរៗ មានសត្វទីទុយហើរកាត់ទៅឆ្ងាយពេលសំឡេងយ៉ាងសៅចិត្ត នាំឲ្យពគ្រែ នោះកាន់តែសម្ងៀមគួរញញើកខ្លាំងឡើង ។

សោភ័ក្ត្រដេកក្តុលក់រសាបរសល់អន្ទះអន្ទែងបែរខ្លួនចុះឡើងលើដំ-ណេក ដូចជាមានអ្វីមកបុកខ្លួនធ្វើឲ្យស្លុតភ័ក្រហាល់ ងើបឡើង អង្គុយសញ្ជប់សញ្ជឹងយ៉ាងទោះម្នាក់ឯង កើតស្រពោនស្រពន់ចិត្តពុំជ្រះ ថ្លា ទើបដកដង្ហើមធំ ទាញក្រដាសជន់បាក់តាមកសរសេរសំបុត្រ មួយច្បាប់ជល់បុត្រីថៃខ្សែល្អស សំបុត្រនោះមានសេចក្ដីជាសង្ខេបដូច្នេះ

ថ្ងៃ ២០ ខែដេសេម្ប្រ៍ ឆ្នាំ ១៩៣០

## មកដល់ប្អូនសម្លាញ់ !

" . . . ថ្ងៃនេះខ្ញុំបងមានទុក្ខធ្ងន់ធ្ងន់ស្ទើរពុំបាន ទើបដាច់ចិត្តសរសេរសំបុត្រមួយច្បាប់ផ្ញើមកដល់ប្អូនឲ្យបានដឹង កុំឲ្យប្អូនទន្ទឹងមើលផ្លូវបង, ដែលបងសរសេរនេះគឺដោយសេចក្តីសោកស្តាយលើសលន់ អក្សរចេញពីដៃទៅដោយលំបាកព្រមនឹងទឹកភ្នែកជោកជុំ ។ សេចក្តីដែលប្អូននឹងមើលទៅនេះមិនជាទីគាប់ចិត្តដល់ប្អូនឡើយ ខ្ញុំបងក៏ពិបាកចិត្តណាស់ដែរ តែពុំដឹងធ្វើដូចម្តេច គួរណាស់តែបងប្រាប់សេចក្តីត្រង់ដល់ប្អូន កាលបើប្អូនបានដឹងហើយបងសង្ឃឹមថា ប្អូននឹងមិនចាប់ទោសអ្វីសដំណើរពីបងឡើយ ទុកជានឹងអាណិតអាសូរដល់សេចក្តីកំសត់ផងបងពុំខាន ។

"ប្អូនអើយ! ប្អូនមើលមេឃទូរទឹមផ្គរត្រហឹមមិនដាច់នាំឲ្យបងស្លុតញាប់ញ័រ ឯអតីតរបស់បងក៏សត់ណាស់ដូចប្អូនដឹងសព្វគ្រប់ហើយ មិនដែលមានថ្ងៃណាបានសប្បាយចិត្តរីករាយនឹងគេទេ តែងស្រពោនសៅនិត្យជាពូជបណ្តុះល្វីងលាស់រៀងរាល់ថ្ងៃ ។ ប្អូន! បងចាំពាក្យដែលបងបានសន្យានឹងប្អូនច្បាស់ថា បងនឹងមិនបណ្តោយឲ្យសេចក្តីកំសត់ញាំញីបាន តែប្អូនអើយ ទុក្ខរបស់បងនេះមិនងាយរសាយទេ ទុកជាមាត់របស់បងប្តេជ្ញាថាក្លេចដូចម្តេច ក៏ផ្ទៃធំពោះនោះគង់ចាប់កើតនៅខាងក្នុងជាពិសេស ។ ខ្ញុំបងសព្វថ្ងៃរស់យ៉ាងដូចកូនសត្វកំព្រាឥតមេ មានតែសម្បុកទទេរវេរវាងវេទនាដាញាប់ញ័រដោយភ្លៀងខ្យល់ មានចិត្តអំពល់ខ្វល់ខ្វាយរកមេរាល់ទិវារាត្រី ម្យ៉ាងទៀតកូនសត្វនោះមិនទាន់ដុះស្លាបក្រាស់នៅឡើយ នឹងហោះស្វែងរកអាហារ ដោយខ្លួនឯងពុំកើត បើដូច្នេះតើនឹងទៅជាដូចម្តេចទៅ ? ...:

"បងដឹងជាក់ហើយថាប្អូនមានចិត្តមេត្តាករុណាដល់រូបបង ប្រាថ្នានឹងធ្វើទ្រុងមាសឲ្យនៅ បំរុងលាងទឹកឃ្មុំឲ្យអាស្រ័យ តែកូនសត្វនោះព្រាត់សម្បុកហើយ កាលណាឡើយនឹងសប្បាយ ។ មួយវិញទៀតឧបមាមច្ឆាដែលធ្លាប់ត្រាច់ត្រាត់ក្នុងទឹកថ្លា នឹងយកទៅដាក់ក្នុងទឹកល្អក់នោះទុកជាត្រាំនៅមិនបានយ៉ាងណា ចំណែករូបប្អូនក៏ដូច្នោះ

ដែរ តើប្អូនធ្លាប់សប្បាយរីករាយដូចបងជា ធ្វើម្ដេចនឹងស៊ូទ្រាំនៅជិតមនុស្សអភ័ព្វដូចយ៉ាងបងបាន ហើយបងក៏មិនចង់បំពុលជីវិតរបស់ប្អូនទៅខាងមុខដែរ ។

“ប្អូនអើយ បងប្រព្រឹត្តខុសធ្ងន់ច្រើនណាស់ តាមតែប្អូនសន្ដោសចុះ បងស្មានថាបើបានប្អូនមកនៅជាគូយនោះនឹងភ្លេចដល់អតីតពុំខាន, ដល់មកឥឡូវទើបយល់ឃើញថាមានសភាវៈអ្វីមកភ្ជាប់នូវទឹកចាស់មិនឲ្យបងសប្បាយបាន ហេតុនេះសូមប្អូនកុំអាក់អន់ចិត្ត បងសូមដកពាក្យសច្ចាដែលបងបានប្ដេជ្ញានឹងប្អូនរួចទៅហើយ . . . “ប្អូន បងនឿយណាយទាំងអស់ហើយឥឡូវនេះ គ្មានអ្វីដទៃទៀតនាំឲ្យបងបានសុខកើតទេ ធម្មជាតិក៏ពុំស្រឡះអាប់អន់ពន់ពេក ពន្លកម៉ឺរដែរជាសហាងស្មើព្រះចន្ទ្រ មានពន្លឺភ្លឹបភ្លែត ហាក់ដូចជាបន្ទប់ពេលនៃមនុស្សរៀបស្លាប់ ដែលទំព្រឹងមិនចង់ឲ្យវិញ្ញាណចាកចោលកាយទៅ ជីវិតបងសោះសូន្យហើយ ខ្លួនបងត្រូវរងាចត្រមង់ឯកោអនាថាក្នុងលោកដ៏ធំនេះ . . . ។

“ប្អូន, បងសូមលាប្អូនហើយ លាគ្រានេះលែងលាទៀត ព្រោះថានៅពេលដែលប្អូនមើលសេចក្ដីនេះ សូរស័ព្ទរបស់លោកលែងឮដល់ត្រចៀកបងហើយ . . . ” ដល់ត្រង់នេះសេចក្ដីក្នុងសំបុត្រខ្ញុំរកមើលពុំបាន ព្រោះជាប់ប្រឡាក់ទៅដោយទឹកភ្នែក . . . ។

សោភ័ក្ត្រ

---

លុះស្រាវសារសំបុត្ររួចហើយ សោភ័ក្ត្រក៏បិទស្រោមការខ្លួនស្រពូល កើតសោកសល់ក្នុងចិត្ត ដើរចុះឡើងពេញតែបន្ទប់សំឡឹងមើលមេឃឃើញខ្មៅងងឹតគួរឲ្យខ្លាច ឃើញដូចជាពពកសោកមកផ្ដុំខ្លួនជុំវិញ នាំឲ្យសោភ័ក្ត្រឈរទ្រឹងរំពឹងគិតថា ខ្លួនអញដល់ស្ថានមច្ចុរាជហើយទេដឹង ។ នៅជុំវិញខ្លួនមានរូបខ្មោច ៗ វិលវល់ចុះឡើងជាគូដងចក្ដៃ

ជីវិតមនុស្ស ពុំមានទ្រង់ទ្រាយជាអ្វី ដើរក្រវែលជុំវិញសោភ័ក្រ្តដូចជាស្រមោលដែលអន្ទោលតាមប្រាណ ពួកនោះគំរាមសោភ័ក្រ្តដោយវិធីផ្សេងៗ មើលទៅឃើញព្រៃព្រឹក្សវ័យដូចចុះអ័ព្ទគួរឲ្យខ្លាចញញើតមហិមា ញើសក៏រងតាមថ្ងាសសោភ័ក្រ្តជាដំណក់ៗ ប៉ុន្តែគាត់ពោតបំពង់កក៏ស្ងួតលេបទឹកមាត់មិនកើត ទើបយកដៃស្ទាបថ្ងាសដើម្បីនឹងកំចាត់បង់នូវគំនិតអាក្រក់ដែលហួលមកគ្រប់គ្រងចិត្ត រួចបានសិតទឹកជិតអស់កន្ទះដប ។

ទ្រាំទឹងអាកាសនោះពុំបាន សោភ័ក្រ្តក៏ចុះដើរតាមថ្នល់ បេះតែដើរទៅមុខទៅមិនដឹងជាដល់ទីណាទេ ទុក្ខដែលកន្ទក់កន្ទេញចិត្តនោះក៏ចោមរោមធ្វើបាបសោភ័ក្រ្តយ៉ាងទារុណស្ទើរប្រេះធ្លាយទ្រូង ចំណែកសង្ខារកង្កាយតាំងប៉ុន្មានគ្មានសល់សរសៃណាមួយ ដែលមិនឈឺក្រហាយទេ ព្រោះសោភ័ក្រ្តស្រឡាញ់ណុជនេត្រនារីដែលហួសពេល ដល់មកអាប់យ៉ាងនេះគួរឲ្យសង្វេគពេកណាស់ នៅពេលនោះសោភ័ក្រ្តនៅស្រឡាញ់នាងដូចដើម រៀងស្អប់នាងពុំបានទេ ឯសេចក្ដីសុខរបស់គេនោះ គឺកង់បន្ទប់ក្នុងលេងពីយ៉ាំណូត់នោះឯង មានតែណុជនេត្រនារីតែមួយដែលអាចនឹងនាំឲ្យគេកើតបាន នេះម្ដងម្ដេចឡើយមកធ្លាយបាត់ទីសុខនេះទៅវិញ មកនឹកសង្ហាកដន្នៃនូវពីយ៉ាំណូត់ទាំងគ្រនាងស្អប់ខ្ពើមមិននិយាយរកមិនមើលមុខទុកជាមនុស្សអាសោចគេតាដូច្នេះ ។

ស្រាប់តែមួយសន្ទុះ មានផ្គរបន្ទោរចាំងក្អកពីទិសឧត្តរហោលពន្លឺ លើមុខសាក់ក្រៃ នាំឲ្យសាក់ក្រៃពេលក្អកវិលមុខដេរដោង ម្សុះ ក៏ទ្រាំងហួចស្រេកទឹកអស់កំលាំងខ្លួនប្រាណ ព្រោះមិនបានដេកហើយមិនបានបរិភោគអាហារអស់មួយថ្ងៃមួយយប់មកហើយ កើតញ័រសាច់ដុល ប្របុលផ្ទប់គេច្រប វិលមុខដើបយកដៃស្ទាបថ្ពាល់ ត្រង់នោះដំរើខ្លួនទៀត ត្រង់ បើកក្អកឡើងឃើញទឹកខ្សៅងងឹតពីមុខ គពីនោះមករសេះរសោះ អស់ដៃជើងទន់ខ្លួនដួលដេកលើផែនដី បាត់ស្មារតីកាលនោះឯង ។

ក្រោយនាយឯណោះ មានភ្លៀងធ្លាក់កក្រលក់ហើយចេះឡើងវិញ តាមអំណាចខ្យល់ រលកក៏គក្រើនក្រោំលន្ទង់លទោបគួរឲ្យខ្លាចពិត ឬនក្ដុញតែរក្រងគុម្ពត្រែងស្បូវល្ហង់ៗ ល្វឹងល្វើយគួរឲ្យស្ញប់ស្ញែង ឬនពោក់មករកព្រាំងលាន់ឆាៗ រូបស្លាក់មួយស្របក់ទៅ នៅវេលានោះឮស្បូរជួបជាអ្វីរមៀលធ្លាក់ក្នុងទឹកប្រង់រូបបាត់ឈឹងស្ងៀម ក្រោយមករលកក្រើនកក្រាំពោរពេញ ហាក់ដូចជាមានទំហំកើនជាងមុនបន្តិច គមកពាក់កាន់តែក្រាស់ឡើង រំង់រគៃកងងឹតលើសដើម ផ្គរគ្រហឹមគឹលមិនដាច់ស្បូវ ខ្យល់គគ្រុកគគាក់លាន់ឮៗ មិនដាច់សោះ បន្ទប់ដែលចំហាក់ត្រូវបំពេញវិញលាន់ក្អាំងៗ ផ្ទុះទ្វេរទ្ធក់ញាប់ញ័រ ខ្លួននាវបកទៅតំពង់យោងយោងទន្ទិបត្អកប្រែណាំ ផ្ដើលដល់អ្នកសំណាក់កន្លោះដើម

គោខ្ញុំឡើងឆេកយេចបេសីមានដំខៀប្រញិបប្រញាប់ តំឡើងនឹមកលើ លោកនេចកខ្វែងជ្រែក, កូនខ្វិកិតកយ៉ៃស្រែតយំឆាំ ។

រន្ទះអសនីបាញ់ផាំងៗមកត្រូវដាច់កំពូលព្រឹក្សអស់ចំនួនច្រើនដើម កក្រើករំពើកអស់វសុធា វិស័យដូចជានឹងក្ដួច កន្ត្រាក់មនុស្សលោក ឲ្យបញ្ចេញពាក្យតាអេត្រា ព្រួញខ្លួនគប់គ្នាស្ទើរតែពុំហាននៅលើគ្រែ ខ្លះក្ដុប ចង្កេះយំឡើងដោយស្រណោះស្រណោកសោកស្ដាយដល់ធម្មជាតិ ដែល ស្រគាំបុះមានសភាពគួរឲ្យស្លុតចិត្ត ទើបនាំគ្នាកាន់មារណសញ្ញាពលៗ របស់គេទឹកភ្នែកជាទុក្ខ, មហាមេឃណែនណាន់តាន់តាក់ខ្លាំង ព្រំមិន ពុនប្រែប្រែភ្ជាយជាច្រើនអន្ទើ សំរក់ផលនៃត្រស្រោបស្រប់ផ្ទៃផែនប្រថពី សូរសន្ធឹកគ្រឹកគគ្រេង ។

នាព្រឹកកាលគួរឲ្យភ័យស្លុតនោះ មានមនុស្សពីរនាក់ដែលមិនបាន ភ្ញាក់ផ្អើលដល់សេចក្ដីវិបត្តិនៃធម្មជាតិ សំឡេងអឹកធឹកនៃលោកមិនបាន ប៉ះពាល់ដល់ត្រចៀកសោភ័ត្រ ដែលកំពុងតក់ចិត្តនូវសេចក្ដីស្នេហា ផ្ដាប់ផ្ដួន ចំពោះណាផ្នែកត្រនារី; ចំណែកនាងវិញ នាងតែងនៅជាសុខ ការពិតតាំងនោះនឹងជាអ្វីដល់រូបនាង? ។. ជីវិតគឺការរស់នៅនេះប្រសើរ ណាស់មិនមែនឬ? ។

(មានត)

*

* *

# ឯកសារមហាស្រាត្រី

ឬខ្ទបពាក់មួយយប់ (ការរៀនអាកំបាំង)

## ភាគទី ១១

## រឿងនាងអាមីន

(តមកពីភាគ ១០)

ការធ្វើបាបផ្ទះផាអំពើប្រទេចតាមចិត្តគណៈសំ ប៉ុន្តែខ្ញុំម្ចាស់អាចនឹងទៅប្តឹងផ្តល់ពីអ្នកណាបាន បើអ្នកធ្វើអំពើនេះក្តីគេទៀតទូត លាចបំពួនអាត្មាបាត់ទៅហើយ ខ្ញុំម្ចាស់មិនអាចស្គាល់គេបានឡើយ: ម្យ៉ាងទៀត បើទុកជាខ្ញុំម្ចាស់ចួបប្រទះហើយស្គាល់ជាក់ប្រាកដក៏ខ្ញុំម្ចាស់អាចពិចារណាឃើញថា អំពើនេះគេត្រូវតែធ្វើតាំងពីកាលយ៉ាងដាច់ខាតផ្ទះចុះ ព្រោះខ្លួនឯងបានប្រព្រឹត្តកន្លងច្បាប់ហែង, បើយ៉ាងនេះតើខ្ញុំម្ចាស់ទៅនឹងប្តឹងរកផ្លូវម្តេចកើត? ។

ខ្ញុំម្ចាស់ជាមនុស្សអនាថាកំព្រាកំព្រាសាត់អណ្តែតសែតអញ្ចឹង គេមិនពឹងពាក់សំណាក់ការស្រែយគ្មាន ទើបចូលមកសូមជ្រកកោននៅជាមួយបើនឹងស្ទើក ដែលទើបទីនិយាយរឿងខ្លួនថាយខែងអម្បាញ់មិញនេះ; ខ្ញុំម្ចាស់បានថ្លែងប្រាប់ពាន់អំពីសេចក្តីកំសត់អភ័ព្វអាភ័ព្វយ៉ាងរបស់ខ្ញុំម្ចាស់, នាងក៏បានទទួលខ្ញុំម្ចាស់ឲ្យនៅជាមួយ ដោយចិត្តសប្បុរសករុណា ហើយនាងក៏ទូន្មានខ្ញុំម្ចាស់ ឲ្យខំតស៊ូទ្រាំសេចក្តីលំបាកវេទនាយ៉ាងនោះឯង

ដោយខ្ទឹងចិត្ត រូបនាងនិយាយតទៅទៀតថា "ប្អូនឯងពិចារណាមើលមនុស្សលោកនេះ គេអាចដកហូតរបស់បំផ្លាញទ្រព្យសម្បត្តិយើង, មិត្តសំឡាញ់យើង, សហាយយើងទាំងរបស់អ្វីទាំងអស់បានតាមអំពើចិត្តគេ" ។ ក្នុងពេលជាមួយគ្នានោះ, ដើម្បីទាញឧទាហរណ៍ពន្យល់ខ្ញុំម្ចាស់ឲ្យឃើញជាក់ស្តែងការអនុវត្តរបស់ខ្លួនផ្ទាល់, ទើបស្ងប់ចិត្តបាន ដំណាលប្រាប់ខ្ញុំម្ចាស់ អំពីសេចក្តីព្រាត់ប្រាសទីកសង្ការព្រះអង្គម្ចាស់ កំព្រា ព្រោះតែបងស្រីតាំងពីមានសេចក្តីប្រច័ណ្ឌ ហើយនាងប្រាប់ខ្ញុំម្ចាស់តទៅទៀតអំពីហេតុដែលតាំងពីក្រោយខ្លួនទៅជាមេផ្ទះ ។ ក្នុងទីបំផុត, លុះបានសិរីដែនមេត្រីភាពជាច្រើនបែបចំពោះរូបខ្ញុំម្ចាស់រួចហើយ ស្តីបន្ទោសបង្ហាញប្អូនស្រីខ្ញុំម្ចាស់ (នាងសាហ៊ី) ដែលបានមកនៅជាមួយនឹងនាងដែរ ក្រោយដែលម្តាយយើងខ្ញុំម្ចាស់ធ្វើមរណកាលទៅ ។

ដោយសារគុណបុណ្យព្រះជួយឲ្យនៅជាសុខសប្បាយ យើងខ្ញុំម្ចាស់បាននៅរួមសុខរួមទុក្ខជាមួយគ្នាជាឯកច្ឆន្ទទាំង ៣ នាក់ មិនដែលមានហេតុអោះអែងឈ្លោះទាស់ទែងខ្វែងគំនិតបែកខ្ញែកពីគ្នាទេ ។ ការណ៍នៅចិញ្ចឹមជីវិតដោយសុចរិតយ៉ាងនេះអស់កាលយូរតមក ខ្ញុំម្ចាស់ទទួលភារៈជាអ្នកត្រួតត្រាខាងការរៀបរយក្នុងផ្ទះសម្បែង ទើបខ្ញុំម្ចាស់ពេញចិត្តនឹងទៅផ្សារខ្លួនឯង ដើម្បីទិញអីវ៉ាន់ផ្សេង ៗ តាមសេចក្តីត្រូវការ ។ ពីថ្ងៃម្សិលមិញ ខ្ញុំម្ចាស់បានទៅទិញអីវ៉ាន់ឯផ្សារ ហើយជួបបុរសម្នាក់ស៊ី

ហ៊ីលល្មាក៏ជាអ្នកធ្លាគកងនៅមានឬកពាថ្ងៃថ្ងៃឲ្យទូលអាក់ននោះឯងមកដល់ផ្ទះ ដើម្បីធ្វើមុខទទួលព្រះកជទានលៀងគ្នាលេងកំសាន្តសប្បាយតាមធម្មតា ។ ពេលព្រលប់លោកអ្នកប្រុស ៣ នាក់ទៅដល់ហើយសូមកន្ទេលសំណាក់ ១ យប់ទ ព្រោះតែព្រឹកឡើងនឹងលានៅ យើងខ្ញុំម្ចាស់ក៏បានយល់ព្រមទទួល ដោយបានដាក់សេចក្ដីបញ្ញត្តិឲ្យប្រតិបត្តិតាមយ៉ាងតឹងរ៉ឹង ; អ្នកប្រុសទាំងនោះ លុះយើងខ្ញុំម្ចាស់រៀបចំឲ្យអង្គុយកៅអីស្រួលបួលហើយ ទើបលេងភ្លេងស្បៀកទ្រីព្រៀងកំសាន្តសប្បាយ តាមបែបដែលគេបេះ ៗ កំពុងតែលេងសើចក្អាកក្អាយទាំងអស់គ្នាដូច្នោះ ស្រាប់តែពួកស្នូរគោះទ្វារប៉ុក ៗ គឺពាណិជទាំង ៣ នាក់ទៅក្រុងមួស៊ូលៃ មានមុខមាត់ស្រស់បស់ ចូលទៅដល់ទៀត ហើយសូមទីសំណាក់ដូចអ្នកប្រុសទាំង ៣ នាក់នោះដែរ; យើងខ្ញុំម្ចាស់បានទទួលឲ្យនៅសំណាក់ដោយដាក់ខបញ្ញត្តិដូចគ្នា ។ ប៉ុន្តែអ្នកទាំងអស់នោះ បែរជាមិនប្រព្រឹត្តតាមខបញ្ញត្តិរបស់យើងខ្ញុំម្ចាស់, ពេលនោះយើងខ្ញុំម្ចាស់មានអំណាចធ្វើទោសទណ្ឌកម្មដល់អ្នកទាំងនោះពេញបន្ទុក, តែបានអនុញ្ញាតលស់លាព្រាប្រណីឲ្យ ដោយគ្រាន់តែបង្ខិតបង្ខំឲ្យនិយាយរឿងរៀង ១ ខ្លួន ប្រាប់យើងខ្ញុំម្ចាស់តែប៉ុណ្ណោះ ហើយបញ្ចប់ការធ្វើទោសទណ្ឌកម្មនោះ ត្រង់បណ្ដេញចេញទាំងយប់លែងឲ្យនៅសំណាក់តទៅទៀតតាមពាក្យដែលសុំពីដំបូង ។

ព្រះបាទកាលីហ្វ៍ ហារុន-អាល់-រ៉ាជិត សប្បាយព្រះទ័យពេកក្រៃ ដោយបានជ្រាបរឿងរ៉ាវដែលទ្រង់ត្រូវការចង់ជ្រាប ហើយទ្រង់សំដែងសេចក្ដីស្ញប់ស្ញែងអស្ចារ្យខ្លាំងណាស់ នាកណ្ដាលជំនុំនោះ ព្រោះរឿងដែលព្រះអង្គទើបនឹងបានទ្រង់ព្រះសណ្ដាប់ហើយនោះឯងជារឿងពិឡែកដ៏ក្រៃពេក ។

រួចហើយទ្រង់សព្វព្រះរាជហឫទ័យនឹងប្រទានអ័ស្ដុតាន ដែនគុណានុភាពនៃព្រះរាជសទ្ធារបស់ទ្រង់ ចំពោះអ្នកបួសជាភិក្ខុត្រទាំង ៣ រូប ហើយទ្រង់បង្ហាញស្រីទាំង ៣ នាក់ ឲ្យបានដឹងច្បាស់នូវផលប្រយោជន៍ដែលជុះជាលផ្សាយចេញមកអំពីដួងព្រះទ័យសប្បុរសរបស់ទ្រង់ ទើបពេលនោះ ព្រះអង្គមិនចាំបាច់ប្រើអគ្គមហាសេនាឲ្យនិយាយជំនួសឡើយ ទ្រង់មានបន្ទូលផ្ទាល់ព្រះអង្គឯងចំពោះនាងសូបីតថា " នៃនាង, ស្រីទេពអប្សរនោះកាលដំបូងដែលបង្ហាញខ្លួនឲ្យនាងឃើញ ដោយក្លែងខ្លួនជាពស់ហើយដែលបានដាក់កំហិតឲ្យនាងយ៉ាងតឹងរ៉ឹង នោះតើបានប្រាប់នាងឲ្យស្គាល់ទីលំនៅរបស់គេឬទេ ? ឬក៏បានសន្យានឹងនាងថាគេនឹងត្រឡប់មកជួបគ្នាពេលណាមួយ ដើម្បីធ្វើមេដៃទាំងពីរនោះឲ្យក្លាយទៅជាមនុស្សវិញដែរឬទេ ? "

នាងសូបីតក្រាបទូលថា បពិត្រព្រះសម្មតិទេព នុំមែនហើយ រឿងនេះខ្ញុំម្ចាស់ភ្លេចក្រាបទូលទ្រង់ឲ្យបានជ្រាប, គឺនាងទេពអប្សរនោះមុននឹង

លាខ្ញុំម្ចាស់ទៅ    បានហុចសក់ ១ កញ្ចប់តូចមកឲ្យខ្ញុំម្ចាស់ហើយផ្តាំថា បើខ្ញុំម្ចាស់ត្រូវការបន់ជួបនឹងគេក្នុងថ្ងៃណាមួយ ឲ្យយកសក់តែពីរសរសៃដុតទៅ, ទោះបីគេនៅឆ្ងាយដល់ទៅខាងឆ្ងាយកំកូកាស ក៏គេអាចនឹងមកជួបនឹងខ្ញុំម្ចាស់បានភ្លាមតាមចិត្តប្រាថ្នា ។ កាលីហ្វ៍ទ្រង់មានបន្ទូលសួរទៀតថា "ចុះកញ្ចប់សក់នោះនៅឯណា?" ។ សុបឹកក្រាបទូលភ្លាមថា តាំងពីពេលនោះមកនាងរក្សាកញ្ចប់សក់នោះទុកជាប់នឹងខ្លួននាងជានិច្ច ដោយហេតុនេះទើបនាងហុចយកកញ្ចប់សក់នោះមក រួចបើកកំរិនដែលបាំងការមុខនាងបន្តិចហើយបង្ហាញឲ្យទ្រង់បានទតច្បាស់ ។ កាលីហ្វ៍មានបន្ទូលតបថា "បើដូច្នោះ យើងត្រូវតែញ៉ើញស៊ីទេពអប្សរឲ្យមកក្នុងវេលានេះកុំខាន គ្មានឱកាសណាល្អជាងឱកាសនេះទេ ដ្បិតខ្ញុំត្រូវការបន់ជួប" ។

នាងសុបឹកយល់ព្រមតាម ហើយឲ្យគេយកភ្លើងមកឲ្យ រួចនាងដុតកញ្ចប់សក់នោះទាំងអស់ទៅ ។ ក្នុងខណៈនោះស្រាប់តែព្រះរាជវាំងញ័ររញ្ជួយទាំងអស់ ហើយលេចនាងទេពអប្សរមកដល់ក្នុងចំពោះព្រះភក្ត្រកាលីហ្វ៍ នាងមានរូបជាស្ត្រីភាពស្រស់ប្រិមប្រិយ ស្លៀកពាក់តែងខ្លួនដោយគ្រឿងអាភរណៈយ៉ាងស្អាត ហើយក្រាបទូលព្រះបាទកាលីហ្វ៍ថា "បពិត្រព្រះភូមិន្ទបរវៃវិសេស, ខ្ញុំម្ចាស់មកដល់ហើយដោយបំរុងនឹងខ្លួនទទួលព្រះរាជឱង្ការរបស់ទ្រង់, អ្នកស្រីដែលទើបនឹងហៅ

ខ្ញុំម្ចាស់ឲ្យមកតាមព្រះរាជបញ្ជាទ្រង់នេះ បានជួយខ្ញុំម្ចាស់ឲ្យរួចពីគ្រោះថ្នាក់យ៉ាងធ្ងន់; ដើម្បីនឹងតបគុណដល់នាងវិញ ខ្ញុំម្ចាស់បានសន្សំធ្វើបងស្រីទាំងពីរ ដែលមានចិត្តទុច្ចរិតក្បត់នឹងនាងនោះឲ្យក្លាយទៅជាមេ-ឆ្កែ; ប៉ុន្តែបើព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យ ខ្ញុំម្ចាស់នឹងធ្វើឲ្យត្រឡប់ក្លាយទៅជារូបប្រក្រតីដើមវិញ ឥឡូវនេះឯង ៗ

កាលីហ្វ៍ទ្រង់មានបន្ទូលថា "នែនាងទេពអប្សរ នាងធ្វើកិច្ចនេះឈ្មោះថាបានបំពេញសេចក្ដីរីករាយយ៉ាងធំដល់ខ្ញុំ, ចូរនាងធ្វើមេឆ្កែទាំងពីរឲ្យក្លាយទៅជាមនុស្សវិញទៅ រួចហើយខ្ញុំនឹងរកឧបាយដើម្បីជួយព្រោមផ្រែននាងទាំងពីរនោះឲ្យបានសុខក្សេមក្សាន្ត ព្រោះគ្នាត្រូវទទួលនូវសេចក្ដីជូរចត់ទុក្ខធ្ងន់យ៉ាងនេះយូរយារណាស់ហើយ . ម្យ៉ាងទៀត ខ្ញុំមានបំណងមួយ ចង់ឲ្យនាងជួយសង្គ្រោះដល់ស្រីម្នាក់ទៀតដែលទទួលទុក្ខទោសគ្រោះថ្នាក់យ៉ាងធ្ងន់ ពីព្រោះតែប្ដីដែលស្រីនោះមិនអាចស្គាល់មុខបាន ៗ ចំណែកខាងនាងជាទេព្ដាអាចដឹងស្គាល់ហេតុគ្រប់យ៉ាងផុតមានទីបំផុត យើងជឿថា នាងមិនមែនជាមិនដឹងទេសព្វបើរឿងនេះ ចូរនាងប្រាប់ខ្ញុំកុំទាំនអំពីឈ្មោះមនុស្សពាលកំណាច ដែលបានធ្វើទុក្ខបុកម្នេញដល់ស្រីនោះហើយថែមទាំងរឹបជាន់ចូនផងហូតប្លន់បំផ្លាញទ្រព្យសម្បត្តិរបស់គ្នាអស់រលីងដោយអំពើខុសច្បាប់ពេញទីទៀតផង , អំពើយ៉ាងនេះជាអយុត្តិធម៌មិនជាមនុស្សធម៌សោះ ៗ ហើយជាអំពើល្មើសទាស់

ខ្ញុំសូមទទួលច្បាប់របស់ខ្ញុំ, សុំកុំឲ្យអំពើអយុត្តិធម៌បែបនេះកើតជាលើកទីពីរ ណាមួយជាថ្មីមកដល់ខ្ញុំទៀតឡើយ" ។

នាងទេពអប្សរទូលតបថា "ដើម្បីបំពេញព្រះទ័យទ្រង់, ខ្ញុំម្ចាស់នឹងធ្វើមេដៃទាំងពីរឲ្យបានវិលត្រឡប់ក្លាយទៅជាភាពដើមវិញ ហើយនឹងធ្វើស្រីដែលមានស្លាកស្នាមក្រដិបក្រដរនោះ ឲ្យបានជាស្អាតបាតដូចដើមដែរ រួចហើយខ្ញុំម្ចាស់នឹងក្រាបទូលទ្រង់អំពីឈ្មោះមនុស្សអប្រិយដែលបានព្យាបាទនាងនោះឯង" ។

កាលីហ្វ ទ្រង់ត្រាស់បើកឲ្យបុរសឲ្យទៅយកមេដៃពីផ្ទះនាងស្ងួតមក លុះនាំយកមកដល់ហើយ ទើបនាងទេពអប្សរសុំឲ្យគេយកទឹក ១ កែវមកឲ្យនាង រួចនាងសូត្រមន្តអាគមខ្សឹបៗ ផ្លុំទឹកកែវនោះ ហើយក៏ជះទៅលើនាងអាមីន ឯមេដៃទាំងពីរក្លាយភ្លាមទៅជាស្រីពីរនាក់មានរូបឆោមយ៉ាងស្រស់ប្រិមប្រិយ ឯស្លាកស្នាមក្រដិបក្រដរនាងអាមីនក៏បានសះជាស្រឡះស្អាតដែរ ។ គ្រានោះនាងទេពអប្សរក្រាបទូលកាលីហ្វថា "បពិត្រព្រះសម្មតិទេព ឥឡូវនេះទ្រង់ត្រូវនឹងរកអ្នកណាជាប្ដីមិនស្គាល់មុខ ដែលទ្រង់ត្រូវការរកឲ្យឃើញនោះ, មិនមែនអ្នកណាដទៃឆ្ងាយឡើយ នៅជិតបង្កើយសោះ គឺព្រះអង្គម្ចាស់ អាម៉ាំង ជាពជបុត្ររបស់ទ្រង់ដែលត្រូវជាព្រះជេដ្ឋានៃព្រះអង្គម្ចាស់ ម៉ាមូន ហ្នឹងឯង ។ ព្រះអង្គម្ចាស់ អាម៉ាំង បានជាមានសេចក្ដីស្នេហាប្រតិព័ទ្ធ

ពីពោះនាងអាមីនខេះខ្លាំងណាស់នោះ ព្រោះទ្រង់បានឮគេសួរសរសើររឿយៗអំពីរូបសម្បត្តិរបស់នាង ទើបទ្រង់តែងបាយកលឲ្យគេទៅល្បួងបញ្ឆោតនាំនាងយកមកដល់ដំណាក់ទ្រង់ ហើយក៏រៀបចំធ្វើអាពាហ៍-ពិពាហ៍ស្វាគតៗក្នុងទីនោះតែម្ដង ។ ចំណែកខាងការព្រយដំបែបដាក់ដែលព្រះអគ្គមហេសីបានប្រែគេឲ្យបៀតបៀនចំពោះរូបនាង ក៏លុមឲ្យអស់ទៅ សាលស់លាក្រាប្រែពពីលើតឡាត់តោលបាន ព្រោះនាងជាកវិយោមាទកវិយោមារយោទក៏មិនសូវគាប់ប្រសើរដែរ ឯការដែលនាងបេះតែនិយាយដោះសាតែសំនួមមិនហ៊ានប្រាប់ដោយត្រង់នោះ អាចឲ្យដឹងថាខ្លួននាងបានប្រព្រឹត្តធ្វើអំពើអាក្រក់ល្មើសខុសច្បាប់ជួរជោះមែន ៗ រឿងរ៉ាវទាំងអស់នេះឯងហើយ ដែលខ្ញុំម្ចាស់ក្រាបទូលដើម្បីបំពេញព្រះទ័យនៃនឹងផ្សាយរបស់ទ្រង់ ។ កាលបញ្ចប់ពាក្យទាំងអស់នេះហើយ នាងទេពកប្បរថ្វាយបង្គំលាព្រះបាទកាលីហ្វ៍ ហើយក៏បាត់ភ្លាមពីទីនោះទៅ ។

ស្ដេចនេះ មានព្រះទ័យពេញទៅដោយសេចក្ដីអស្ចារ្យស្ញប់ស្ញែងពីពន្លឺ ហើយទ្រង់រកព្រះទ័យណាស់នឹងការប្រែប្រួលដែលទើបនឹងបានសម្រេចដោយសារបាយកលរបស់ព្រះឥន្ទ្រ; រឿងដែលទ្រង់បានធ្វើនេះទុកជាព្រះកេរ្តិ៍ដំណែលនាំឲ្យអ្នកផងដំណាលសរសើរព្រះកិត្តិនាមរបស់ទ្រង់ ជាប់តទៅក្នុងអនាគតកាល ។ មុនដំបូងព្រះឥន្ទ្រ

បានឲ្យហៅ អាម៉ាំង ឲ្យព្រះភក្ត្រមក ហើយមានបន្ទូលថា ទ្រង់បានជ្រាបទាំងអស់នូវកិច្ចអាពាហ៍ពិពាហ៍ដោយស្ងាត់កំបាំងរបស់ខ្លួន រួចទ្រង់មានបន្ទូលប្រាប់រាជបុត្រអំពីដើមហេតុដែលនាងអាមីនមានរបួសត្រង់ថ្ពាល់ ៗ ព្រះអង្គម្ចាស់អាម៉ាំងមិនបាច់ឲ្យព្រះបិតាបង្គាប់ថា "ឯងចូរយកនាងអាមីនវិញទៅ" ដូច្នេះទេ ទ្រង់ទទួលយកនាងវិញភ្លាម ដោយព្រះទ័យព្រះអង្គឯងក្នុងពេលនោះហោង ៗ

លំដាប់នោះព្រះបាទកាលីហ្វ មានបន្ទូលសុំយកនាងសូប៊ីដធ្វើជាព្រះស្នំ ហើយរៀបចំទុកដាក់ផ្ដុំបងប្អូន ៣ នាក់ទៀត (នាងពីរនាក់ដែលទើបនឹងក្លាយមកពីមេឆ្កែ ហើយនឹងនាងសាហ្វី) ឲ្យអ្នកបួសទាំង ៣ រូប ដែលជាជាតិក្សត្រ; អ្នកទាំងនោះក៏ទទួលយកនាង ៣ នាក់ធ្វើជាភរិយារបស់ខ្លួន ៗ ដោយសេចក្ដីដឹងព្រះគុណដ៏លើសលុប ៗ ព្រះបាទកាលីហ្វបានប្រទានកំណាន់យ៉ាងល្អដល់ក្ដុមផ្ទះទាំងនោះឯងមួយ ៗ គ្នា ឲ្យនៅក្នុងក្រុងបាគដាទ, ទ្រង់តែងតាំងជនទាំងឡាយនោះជាបន្ទុកទី ១ ក្នុងព្រះនគរ ហើយលើកដំកើងតាំងឲ្យជាអ្នកជួយប្រឹក្សាកិច្ចការរាជការរបស់ទ្រង់ ៗ រួចហើយព្រះអង្គឲ្យហៅទៅក្រមទី ១ ក្នុងក្រុងបាគដាទព្រមទាំងសាក្សីជាច្រើនរូបមកឲ្យធ្វើសំបុត្រសញ្ញានៃអាពាហ៍ពិពាហ៍ ៗ ព្រះបាទកាលីហ្វ ហារុន-អាល់-រ៉ាស៊ីត ដ៏មានព្រះកិត្តិនាមល្បីល្បាញ ការដែលទ្រង់បានយកព្រះរាជហឫទ័យទុកដាក់ ជួយសង្គ្រោះពួកជនទាំងឡាយ

ដែលត្រូវទទួលគ្រោះថ្នាក់ធ្ងន់ធ្ងរនោះឯងទៀត បំពុកសុខសាន្តត្រាណហ៊ាននេះហើយ ព្រះអង្គក៏បានបំរើនគរបពិត្រដោយព្រះភក្តីយសនឹងសិរីសួស្តីជ័យមង្គលជាកិរយោភាព ។

ឆានសែកសាជ និយាយរឿងនេះចប់ហើយ ពេលវេលាមិនទាន់ភ្លឺនៅឡើយ មានឱកាសល្មមផ្តើមនិយាយរឿងផ្សេងក្រៅទៀតបាន ទើបនាងចាប់ផ្តើមដំណាលរឿងមួយទៀតទូលព្រះបាទសារ្យា ដូចសេចក្តីតទៅនេះ ។

ចប់ភាគទី ១១ តែប៉ុណ្ណោះ

ស្តាយណាស់ស្រ្តីមិនបានធ្វើអ្នកបួសទាំង ៣ នាក់ឲ្យបានជាក្មេកផងសោះ ។

រឿងក្នុងភាគទី ១២ ពីរោះណាស់

សូមអញ្ជើញមើលតទៅកុំខាន ។

# ព្រះបាទសម្តេចព្រះជ័យជេស្ឋា (ព្រះអង្គស្ងួន)

(តទៅ)

បណ្តាពស្រីនៅភូមិជិតតាំងប៉ុន្មាន ឲ្យស្តាប់បង្គាប់គេឡាពាសហ្វូង (ហុក) តាំងរៀបរបស់ គេឡាពាសហ្វូង (ហុក) បានក្រាបបង្គំទូលសុំទីជីកោអបំបក់ទៀតគឺទ្រង់ព្រះរាជទាន រូបស្តេចចេញពីគោអបំបក់ទៅដល់ស្ទឹងទទឹងថ្ងៃទ្រង់ប្រថាប់នៅទីនោះ ។ គេឡាពាសហ្វូង (ហុក) ក្រាបទូលថាកាលទូលព្រះបង្គំជាខ្ញុំកើតស្រុកឃ្មែរ នឹងសម្តេចព្រះបទុមរាជា (ព្រះអង្គនន្ទ) បានច្បាំងឈ្នះទ័ពយួន-ខែរនៅស្ទឹងទទឹងថ្ងៃនេះ ដេញការសម្លាប់យួន-ខែរនៅបឹងខាងណោះជាច្រើន ៗ ទ្រង់មានព្រះរាជឱង្ការថា បើដូច្នោះ ស្ទឹងនេះត្រូវប្រែឲ្យឈ្មោះថា ស្ទឹងមានជ័យ (អ្នកស្រុកហៅថា ស្ទឹងអន្ទ័យ) បឹងនោះឲ្យហៅថា បឹងក្បាលយួន លុះដល់សព្វថ្ងៃនេះ ៗ

## ទ្រង់ប្រាប់ប្រាមពួកក្បត់

ក្នុងឆ្នាំមមែសក (ព.ស. ២២៣៨) ព្រះអង្គអុកជោតុ ១ ព្រះអង្គអុកទុត ១ នឹងពួកព្រះវង្សនៅខេត្តស្រីសឈរ ដែលជាព្រះញាតិនឹងសម្តេចព្រះបទុមរាជា (ព្រះអង្គនន្ទ) បញ្ចុះបញ្ចូលរាស្ត្រតាំងជាកងទ័ពបានចំនួនពលជាច្រើន ៗ

ព្រះបាទសម្តេចព្រះជ័យជេដ្ឋា ទ្រង់ជ្រាប ស្តេចរាក់សម្តេចព្រះស្រីទៀវ (ផង) ឲ្យលើកសេនាទាហានទៅតាមចាប់ព្រះអគ្គអគជាត ព្រះរាជអគ្គទុកឪពុកបក្សពួកនាំមកថ្វាយ ទ្រង់ឲ្យសេនាបតីជំនុំជម្រះបាត់ទោស ទីប្រជុំយល់ព្រមគ្នាថា ត្រូវសម្លាប់តាមទោសកំហុស ទើបពួកក្បាក់ដាក់នាំខ្លួនទាំងពីរនាក់ ទីឪពុកពួកយកទៅប្រហារជីវិតនៅព្រៃយាញ់ លេខ្ទះឲ្យរៀបចំពលជាពលរបស់ប្រាប់សម្តេចព្រះស្រីទៀវទាំងអស់ ។

## ទ្រង់ប្រជុំរើសតាំងមន្ត្រីជាន់ខ្ពស់និងរៀនចម្បាប់

ក្រោយនោះមក ស្តេចព្រះពញាពណ៌ទៅប្រថាប់នៅព្រះពន្លាក់កទួលព្រះស្រីហើយត្រាស់ឲ្យប្រជុំសេនាបតីព្រះរាជាគណៈ បារគូប្រ៊ោហិតហោរាចារ្យ មកជំនុំជុំរើសទីស្រុកាធិបតី ទីងទៅហ្វាយឃ្លាំងទាំង ៤ ទៅហ្វាយស្រុក ១០ ហ៊ុំពាន់ ខែត្រក្រៅ ។ ត្រូវរើសខុំពជប្បារណាដែលមានគំនិតខ្ជាប់ខ្ជួនបេះបញ្ជាប់ទម្លាប់ទំនៀម បេះព្រះត្រូវជាកខឹងកន្ទាក់ច្រើន ទីប្រជុំយល់ឃើញថា ហ៊ុនអ៊ុក ដលបួសបេះព្រះត្រូវជាកខឹងកន្ទាក់ច្រើន ទើបទ្រង់ព្រះមេត្តាប្រោសតាំង ហ៊ុនអ៊ុពជាឧកញ៉ាសុភាធិបតី ។ ចៅពញា (អ៊ី) ជាឧកញ៉ាបរិនាយក ។ ហ៊ុនមាស ជាឧកញ៉ារាជនាយក ។ ហ៊ុនពា ជាឧកញ៉ាពលទេព ក្រសួង-ពិភក្តី ។ ហ៊ុនខុច ជាឧកញ៉ាពិពិធសាលីធិបតីខ្មែរ ។ ហ៊ុនសួស

ជាចៅហ្វាយស្រុកខែត្របាភ្នំ ។ ឧកញ៉ាបរមពិភក្តិ (គង់) ជាចៅហ្វាយស្រុកខែត្រក្រូចឆ្មារ ។ ហ្លួនទៀន ជាចៅហ្វាយស្រុកខែត្រពោធិ៍សាត់ ។ ហ្លួនកូវ ជាចៅហ្វាយស្រុកខែត្រកំពង់ស្វាយ ។ ហ្លួនឯក ជាចៅហ្វាយស្រុកខែត្រនគរសៀមរាប ។ ហ្លួនប៉ាង ជាចៅហ្វាយស្រុកខែត្រស្រីសណ្ឋរ ។ ហ្លួនលី ជាចៅហ្វាយស្រុកខែត្របរិបូណ៌ ។ ហ្លួនគាំ ជាចៅហ្វាយស្រុកខែត្របាត់ដំបង ។ ហ្លួនមា៉ ជាចៅហ្វាយស្រុកខែត្រត្រៃក្តី ។ ហ្លួនឡុង ជាចៅហ្វាយស្រុកខែត្រសំបុក ។ នាយសែនផលពាន់ទង់ជ័យទ័ពហួន ជាចៅហ្វាយស្រុកខែត្រសំបូណ៌ ។ ហ្លួនគាំ (ប្រហែលជាម្នាក់ទៀត) ជាចៅពញាទេសាស្នេហា ប្រគល់ឲ្យគ្រប់បង់ខ្សែឲ្យចៅពញាទេសាស្នេហា ត្រាស់បង្គាប់ឲ្យទៅនៅភូមិកំពង់ត្រឡាក់ខែត្រភ្នំពេញ ។ ចៅពញា (នុក) ជាចៅពញាស្នេហានុជិតឲ្យស្រដីលើកូនចិនកងត្រង់ ១ ខែត្របាភ្នំ ១ ខែត្រពាមជរ ១ ស្រុកព្រៃហ្លួង ១ ខែត្រសំបូណ៌ ១ ស្រុកទ្រាក់ ១ ស្រុកស្គរ ១ ។ ហ្លួនជ័យ ជាចៅពញាទេសវង្សាឲ្យស្រដីលើកូនចិនខែត្របាសាក់ ១ ព្រះត្រពាំង ១ ក្រមួនស ១ ។ ចៅពញា (ពេជ្រ) ឲ្យធ្វើជាឧកញ៉ាអធិបវង្សា ចៅហ្វាយស្រុកខែត្របាសាក់ ។ ហ្លួនមូរ ជាចៅហ្វាយខ្លាង ។ ហ្លួនជា ជាចៅ-ហ្វាយស្រុកខែត្រលាវៀរ ។

លុះថ្ងៃក្រោយមក ទ្រង់មានព្រះរាជឱង្ការឲ្យនាយគោចូលគាល់ ហើយទ្រង់ត្រាស់បង្គាប់ឲ្យឧកញ៉ាមហាមន្ត្រី-មហាទេព រៀបរាក់-ហមន្ត្រីផ្សេងៗនាំនឹងនាយគោ ជាស្វាមីរក្សារូបស្រេច ស្ដេចទ្រង់ព្រះមេត្តាប្រោសតាំងនាយគោជាឧកញ៉ាមន្ត្រីស្នេហា ទៅហ្វាយស្រុកខែត្រគោកសេះ ។

ទើបទ្រង់ព្រះរាជបញ្ញត្តថា តាំងពីថ្ងៃនេះទៅ មន្ត្រីតាំងពីស័ក្តិ ១០ ហ៊ូពាន់ចុះមក វេលាដែលឡើងយសស័ក្តិ ត្រូវឲ្យរៀបស្លាព្រះតៅផ្ដាក់ទៅមានទៀនគោលតាមស័ក្តិ ត្រូវឲ្យឧកញ៉ាមហាមន្ត្រី-មហា-ទេព នាំឡើងក្រាបថ្វាយបង្គំទូលព្រះតេជះព្រះពារ ហើយទាន់ផុតថ្វាយបង្គំទេវតាមិនតេញទៅព្រះរាជបញ្ញត្តនេះ មានកុនត្រៃមព្រះរាជបន្ទូលស្រាប់ ។

## ទ្រង់កសាងព្រះរាជវាំងថ្មីនៅបឹងក្សៀន

លុះតាំងខ្ញុំរាជការឲ្យឡើងយសស័ក្តិរួចស្រេច ស្ដេចទ្រង់ប្រឹក្សានឹងសេនាបតីមន្ត្រីទាំងពួងថា យើងមកនេះហោយបំណងនឹងធ្វើព្រះរាជ-វាំង គង់នៅទីទួលព្រះស្រីនេះ យើងមិនបង់ត្រឡប់ទៅគង់នៅព្រះរាជវាំងចតុមុខវិញទេ តែឥឡូវនេះ ទីនេះចង្អៀតណាស់ គឺកែមិឯណាឲ្យបានស្រឡះទូលាយនោះ ព្រះសុគ្រាមមុនី (ភី) គង់វត្តចេតិយបពិត ព្រះពោធិវង្ស (ឯក) គង់វត្តឧណ្ណាលោមថ្វាយព្រះពរថា

ឃើញតែទីបឹងកៀនខ្ទលាយមានជ័យភូមិល្អ គួរសាងព្រះរាជវាំងបាន ។ ទើបទ្រង់ព្រះមេត្តាប្រោស អកបាំនជំនិតសាទ្រង់ ឲ្យឡើងយសសក្តិជាឧកញ៉ាវង្សាធិបតី ។ ប្អូនពជាមាត្យ ( ម៉ែន ) ជាឧកញ៉ាស្រីធិបេស្រ្វ រាជាជាចៅហ្វាយព្រះសុរិយោដី ។ រួចទ្រង់ត្រាស់បង្គាប់ឲ្យមន្ត្រីតាំងពីរនាក់ បញ្ចេញទៅតេណ្ឌុកស្រូតកាប់ឈើធ្វើព្រះរាជវាំងតំណាក់ធំ-តូច នៅទីទួលបឹងកៀន រួចហើយទើបហោរាធិបតី (ជួរ) ពិនិត្យឫក្សហ្វាយ នឹងឡើងគង់ព្រះរាជវាំងថ្មីឲ្យទ្រង់បានប្រាប ។

ទ្រង់តាក់ឲ្យនិមន្តព្រះសង្ឃរាជាគណៈហ៊ានុក្រម បំរើនព្រះបរិត្តក្នុងព្រះរាជវាំងថ្មី ៣ ថ្ងៃ ។

លុះដល់ថ្ងៃព្រហស្បតិ៍ ១១ កើតខែបុស្សឆ្នាំចសំរឹទ្ធិស័ក ពុទ្ធសករាជ ២២៣៨ ស្តេចអញ្ជើញសម្តេចព្រះកន្ទ្រាន ព្រមទាំងនាំព្រះអគ្គមហេសី ព្រះសុំស្រីផ្គារ សេនាបតីមន្ត្រីខ្ញុំរាជការគ្រប់ក្រុម ស្តេចព្រះរាជដំណើរចេញពីព្រះពន្លាក់អន្ទូលព្រះស្រីទៅគង់នៅព្រះរាជវាំងបឹងកៀន ពួកសេនាបតីមន្ត្រីខ្ញុំរាជការ ក៏តាំងភូមិលំនៅទៅជិតព្រះរាជវាំង ។

ថ្ងៃក្រោយមក ទ្រង់ព្រះប្រាព្ធនឹងសេនាបតីមន្ត្រីថា ទ្រង់នឹងកសាងព្រះវង្សណាមួយ ដែលមានពុទ្ធសុចរិតទៀងត្រង់គំនិតទារយោងខ្ជាប់ខ្ជួន ទ្រង់នឹងតាំងជាព្រះអគ្គរាជាធំលើអស់ព្រះវង្ស ។ ពួកសេនាបតីទូលថា ទូលព្រះបង្គំជាខ្ញុំឃើញព្រះសុធនបុត្រ (រស់) ១ ព្រះអភ័យទេស

(អ៊ី)១ មនុស្សទាំងពីរនេះជាមនុស្សចាស់សុចរិតត្រង់ទឹកដៃនដី ។ ហើយទ្រង់ត្រាស់ឲ្យអ្នកទាំងពីរចូលគាល់ ហើយទ្រង់ព្រះមេត្តាប្រោសព្រះសុពនបទ (សេ) ឲ្យឡើងយសសក្តិជាសម្តេចព្រះអគ្គតៃ ចំបងលើអស់ព្រះវង្ស ។ ព្រះអភ័យទេស (អ៊ី) ជាសម្តេចចៅហ្វាទឡ្ហៈ ។

ព្រះបាទជីកា (នូម) ជាសម្តេចចៅពញា ចំបងលើសេនាបតីខាងឧបយោរាជ ។ ទ្រង់ថ្វាយមន្ត្រីសម្រាប់ខាងឧបយោរាជ ទៅសម្តេចព្រះវរកេវផងនីទាំងអស់ ។

ទ្រង់បញ្ញត្តថា រីឯត្រដើងព្រៃ ត្រូវឡើងសម្តេចព្រះអគ្គតៃ ។ រីឯត្រកំពង់ស្វាយនិងកំឡោះក្លូនចិន និងពួកអ្នកលេងល្បែងសៀម ឡើងសម្តេចចៅហ្វាទឡ្ហៈ ។ ពួកកញ្ចៀនគីអុំស្ទូ ឡើងសម្តេចចៅពញា ។ រីឯត្រចុងកំពង់ស្វាយទាប ឡើងឧកញ៉ាបក្រែ ។ រីឯត្រត្បូងឃ្មុំឡើងឧកញ៉ាក្រឡាហោម ។ រីឯត្រព្រាំងឡើងឧកញ៉ាយមរាជ ។ រីឯត្រពាធិសាត់ ឡើងឧកញ៉ាកំង ។ រីឯត្រក្រៅពីនេះត្រូវឡើងតាមក្រសួងតាមលំដាប់ ៕ —

ថ្ងៃមួយ ចៅពញាទេសស្នេហាក្រាបទូលថា ខ្ញាំចំបងថ្លៃ ទ្រង់ត្រាស់ប្រើក្រឡាពាសហ្នូន (ហុ[illegible]) ឲ្យទៅចាប់ខ្វា ក្រឡាពាសហ្នូនថ្វាយបង្គំលាចេញមកយកបាវម្នាក់ឈ្មោះស ឲ្យតាន់លំពែងនឹងបក្ខពួកប្រើនគ្នា យកទាំងថ្លៃឈ្មោះអាស្រែតំទៅផង ។ លុះនាំគ្នាទៅដល់ព្រៃ

កាក្រសិនឃើញខ្លាអាំដេញក្របីសកោះ ក្រឡាពាសហួន (ហុក) និងឈ្មោះ
រស់ចូលទៅឧឹងចាក់ខ្លា១ស្ទុះលោតមកខាំ នោះឈ្មោះរស់មានថ្ពៃរបួស
ទទួលធាក់ត្រូវ ក្រឡាពាសហួនក៏ចាក់ខ្លានោះថែមស្លាប់នៅទីនោះ
ទៅហើយចាក់មណ្ណកស្លេក្តន្សៃស៊ខ្លាមកថ្វាយនៅព្រះបរមរាជវាំង ទ្រង់
មានអំណរណាស់ ស្តេចសរសើរអគតាំងពីរដោយប្រការផ្សេងៗ ទ្រង់
ព្រះរាជតានឲ្យក្រឡាពាសហួន (ហុក) គឺការព្រៃឡមាស ១ ដែលព្រះ
គន្ធទ្រង់ទឹងសំពត់ហូល ១, ទ្រង់ព្រះរាជតានឈ្មោះរស់ គឺសំពត់ ១
អាវ ១, កន្លែងដែលចាក់ខ្លាស្លាប់នោះកន្លែងក្រហំពេញតោះឲ្យហៅថា ភូមិ
ខ្លាក្រាបរៀនមក ។

## ទ្រង់ប្រជុំរៀបរៀងផ្ទៀងផ្ទាត់ព្រះរាជក្រឹត្យ ២៤ ក្រម

ថ្ងៃក្រោយមក ទ្រង់ព្រះរាជបញ្ជាឲ្យការញាំយេបរាជធិនមន្ត្រីខ្ញុំរាជការ
ឲ្យចេញទៅធ្វើព្រះគន្ថាភ័តនៅអូរឬស្សីក្រងលាយអំ ហើយស្តេច
អញ្ជើញសម្តេចព្រះវរាជវងខ ព្រមទាំងអគ្គមហេសីព្រះស្នំស្រីគ្គារ
សេនាបតីមន្ត្រីខ្ញុំរាជការគ្រប់ក្រុម ព្រះរាជដំណើរចេញពីព្រះរាជវាំងបវរ
វិក្យន ទៅប្រថាប់នៅព្រះពន្លាអូរឬស្សីក្រងលាយអំ នាហ្ម៉ឺនសព្វមុខ
មន្ត្រីក្រាបបង្គំគាល់នៅត្រៀបត្រា ១ ទើបស្តេចឲ្យនិមន្តព្រះសុគន្ធាធិបតី
ជាសង្ឃនាយក ព្រមទាំងសេនាបតីមន្ត្រីខ្ញុំរាជការ ចកគាល់ដូចជុំទ្រង់
ព្រះត្រាស់ថា ច្បាប់អំពីបុរាណដែលយើងប្រើសព្វថ្ងៃនេះក៏ឯណាស់

លោះនេះគួរយើងរៀបរៀងឲ្យត្រឹមត្រូវល្អ ត្រង់ណាដែលធ្ងន់ណាស់ បន្ថយឲ្យស្រាលឡើង យើងបានរៀបរៀងផ្ទៀងផ្ទាត់មកខ្លះតែពុំទាន់ចប់ ឥឡូវត្រូវយើងផ្ទៀងផ្ទាត់ឲ្យចប់សព្វគ្រប់ ហើយតាំងសករាជឲ្យត្រឹមត្រូវទុកជាព្រះកេរ្តិ៍ ឲ្យមហាក្សត្រអង្គក្រោយប្រព្រឹត្តតាម ៗ សម្ដេចព្រះសុគន្ធាធិបតីនិងសេនាបតីមន្ត្រីផងថ្វាយព្រះពរ ក្រាបបង្គំទូលថា ដែលទ្រង់ព្រះតម្រិះនេះប្រពៃណាស់ ត្រូវតាមព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រដែលទ្រង់ប្រកបដោយព្រះវិរិយព្យាយាម រៀបចំព្រះនគរឲ្យចម្រើនរុងរឿងសុខសប្បាយ ដល់គណាប្រជាជនតទៅ ៗ

ទើបទ្រង់លើកច្បាប់ ២៤ ក្រម ឲ្យមន្ត្រីស្រដីដោយមុខងារទុកនៅ ដែលកញ្ញាមន្ត្រីគញ្ចិក ជាព្រះរាជអាជ្ញាព្រះរាជពេន ឲ្យប្រើគ្រប់មន្ត្រីធំ - តូច ស្ដេចប្រថាប់នៅទីនោះ ១ ខែ ក៏ស្ដេចព្រះរាជដំណើរចេញពីព្រះពន្លាក្បូរថ្មស្រីគ្រងលាយធំ ទៅគង់នៅព្រះបរមរាជវាំង នគរឧត្តុង្គឫជ័យវិញ ៗ

ក្រោយនោះ ទ្រង់ឲ្យប្រជុំសម្ដេចព្រះសុគន្ធាធិបតីនិងព្រះរាជាគណៈ ព្រះរាជគ្រូបុរោហិតហោរាចារ្យសេនាបតីមន្ត្រីទាំងពួង ជំនុំពិនិត្យផ្ទៀងផ្ទាត់ព្រះច្បាប់ទាំង ២៤ ក្រមហើយស្រេច តាំងសករាជ នាំសេចក្ដីខាងដើមថា សុភមស្តុសួស្ដីសិរីសុភមង្គលពហុលប្រសុភ ផលាតិរេក ............ ៗ

ថ្ងៃចន្ទ ៣ កើតខែកត្តិក ឆ្នាំចឆស័ក ជាថ្ងៃបានឫក្សពេលមង្គលក្នុង អំពីព្រះរាជហ្ឫទ័យ នៃព្រះបាទសម្តេចព្រះជ័យជេស្តាពិមានស្វរបរមេ-ស្វរិន្ទបរមបពិត្រជាអម្ចាស់ជីវិតលើត្បូង ស្តេចចេញប្រថាប់នៅចុងព្រះរាជវាំងមានពួកសេនាបតីមន្ត្រីខ្ញុំរាជការអង្គុយគាល់តាមលំដាប់ ទ្រង់មានព្រះរាជឱង្ការទីងសេវកាងាត្យទាំងនោះថា ព្រះមហាក្សត្រដែលនឹងគ្រប់គ្រងរក្សាព្រះនគររក្សាផែនដីទៅអនាគត ទីងនាហ៊ឺនសព្វមុខមន្ត្រីខ្ញុំរាជការឲ្យប្រតិបត្តិតាមព្រះច្បាប់នេះ បើព្រះច្បាប់ឯណាមិនត្រូវនឹងព្រះនាមអញ សងរាជអញកុំឲ្យយកឡើយ បើត្រូវនឹងព្រះនាមអញ សងរាជអញសំមឲ្យយក ៗ ហើយទ្រង់ឲ្យចែកជាក្រមៗ ទៅដូចជាក្រមស្រុកាធិបតី ក្រមចែកមុខមុកនៅដៃឧត្តញ៉ាមន្ត្រីអញ្ជិត ក្រមទសករិយា ក្រមចែកពល ក្រមវិវាទ ក្រមស្រុវឹងសង្ស ក្រមពលទេព ក្រមគោ ក្រមសេះ ក្រមទូក ក្រមស្បូវ ។ល។

ព្រះបាទសម្តេចព្រះជ័យជេស្តាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ប្រកបដោយព្រះបារមីឧត្តមប្បការៈគុណព្រះរត្នត្រ័យ ទ្រង់រក្សាសីលទ្រង់បរិច្ចាគទានជានិច្ច ទ្រង់ព្រះមេត្តាករុណាបណ្តាពស្តួតទាំងពក ព្រះនគរក៏ចំរើនរុងរឿងសុខក្សេមក្សាន្ត ទាំងភ្លៀងក៏ធ្លាក់ត្រូវតាមរដូវការ ស្រូវនូវផលាផលក៏បរិបូណ៌ក្នុងរាជ្យនោះ ស្រូវ ៥០០ ថាំងថ្លៃជាប្រាក់ ១ ណែន ។

## ទ្រង់បង្វែររាជ្យព្រះរាជទានព្រះឧទ័យរាជា

លុះដល់ឆ្នាំកុរសប្តស័ក (ព.ស. ២២៣៩) ទ្រង់ព្រះពិចារណាឃើញភ័យហេតុនៃវដ្តសង្សារ មានព្រះទ័យប្រាថ្នាព្រះពោធិញ្ញាណ ដើម្បីនឹងដោះទុក្ខសត្វលោកទាំងពួង ព្រះអង្គគ្រាន់អភិសេកសោយរាជសម្បត្តិបាន ២ វស្សា ។

ទើបទ្រង់ប្រជុំសេនាបតីមន្ត្រីទូកដការមកជួបជុំ ទ្រង់ត្រាស់ថា យើងនឹងបង្វែររាជ្យព្រះរាជទានព្រះឧទ័យរាជា (ព្រះអង្គយ៉ង់) ជាភាគិនេយ្យឲ្យសោយរាជសម្បត្តិ អស់អ្នកទាំងពួងយល់ដូចម្តេច ។ សេនាបតីមន្ត្រីទាំងនោះ ក៏យល់ព្រមតាមព្រះរាជប្រះ រួចទ្រង់ព្រះរាជបញ្ជាឲ្យក្រសួងនិងឲ្យរៀបពិធីតាមទំនៀម ស្តេចបង្វែររាជសម្បត្តិព្រះរាជទានព្រះឧទ័យរាជា(១) ជាព្រះភាគិនេយ្យឲ្យសោយរាជសម្បត្តិតាមព្រះប្រវេណី ។ (មានត)

---

១ ច្បាប់ពោះពុត្តភាសាថៃថា ក្នុងឆ្នាំកុរព្រះបាទសម្តេចព្រះជ័យជេដ្ឋា ព្រះជន្មបាន ៣៤ វស្សា ស្តេចប្រថាប់នៅក្រុងឧត្តុង្គឫជ័យ ទ្រង់បង្វែររាជសម្បត្តិព្រះរាជទានព្រះឧទ័យរាជាជាព្រះភាគិនេយ្យ ព្រះជន្ម ២១ ឆ្នាំឲ្យឡើងគ្រងរាជ្យ ។ តែច្បាប់សាស្ត្រាស្លឹករឹតថាទ្រង់បង្វែររាជសម្បត្តិឲ្យចៅពញាយ៉ង់ ជាព្រះរាជបុត្រព្រះអង្គជី នោះព្រះជន្ម ២៣ វស្សាឲ្យឡើងគ្រងរាជសម្បត្តិ ។ ច្បាប់ពង្សាវតារ (Cao-Men-ky-Luoc សេចក្តីថា ណា-យី-ទ្រិ-ស្វ-ថា-ស្វ ទ្រង់លះបង់រាជសម្បត្តិប្រទានព្រះភាគិនេយ្យ សា-អ៊ូ-ទី (ព្រះឧទ័យរាជា) ជារាជបុត្រ ពោ-សា-ចល់-តុយ-អុក-ធី ស្តេចនេះទិវង្គតទៅដាច់ពកនៅចុកឆ្នាំនុះឯង ព្រះជន្ម ២២ វស្សា (1695) ។

# ធម្មវិភាគ

## ព្រះគ្រូសុវណ្ណញ្ញាណ សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

## រៀបរៀង

ប្រែតាមអត្ថនិទ្ទេសវិគ្គហៈរបស់ធម្មៈ

ពាក្យថា ធម្មៈ ឬធម៌ ព្រះសម្ពុទ្ធទ្រង់សំដែងសំដៅយកសេចក្តីច្រើនយ៉ាងដែលជាប់មានប្រាកដមកក្នុងគម្ពីរព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្មដោយច្រើន ពាក្យនេះហាក់ដូចជាសម្រាប់ប្រើសាធារណៈក្នុងទីផ្សេងៗ ស្រេចហើយតែនឹងសមគួរទៅតាមដំណើរសេចក្តីដូចតទៅនេះ:

១ - ធម្មៈ ប្រែថា "សភាវៈគឺសេចក្តីពិត ឬជាចិត្តនឹងចេតសិកជាកុសល, អកុសលនឹងអព្យាកតៈ" ដូចបទថា: កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ។

២ - ធម្មៈ ប្រែថា "ប្រាជ្ញា" ដូចបទថា: សច្ចំ ធម្មោ ធិតិ ចាគោ, សច្ចៈ ធម្មៈ ធិតិ ចាគៈ (នេះជាឃរាវាសធម៌) ពាក្យថាធម្មៈ ក្នុងទីនេះ ជាឈ្មោះប្រាជ្ញា ។

៣ - ធម្មៈ ប្រែថា "បុណ្យ" ដូចបទថា: ធម្មោ ហវេ រក្ខតិ ធម្មចារឹ បុណ្យហ្នឹងឯងរមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ ។

៤ - ធម្មៈ ប្រែថា "បញ្ញត្តិ ឬលំនាំភាសាគឺបង្គាប់ដែលគេតាំងទុកនឹងលំនាំសំឡេង" ដូចបទថា: បញ្ញត្តិធម្មា និរុត្តិធម្មា ធម៌គឺបញ្ញត្តិ ធម៌គឺលំនាំភាសា ។

៥- ធម្មៈ ប្រែថា "អាបត្តិ" ដូចបទថា: ចត្តារោ បារាជិកា ធម្មា អាបត្តិបារាជិក ៤ ។

៦- ធម្មៈ ប្រែថា "បរិយត្តិគឺព្រះសិក្ខា" ដូចបទថា: ឥធ ភិក្ខវេ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ ។ល។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះតែងរៀនត្រៃបរិយត្តិគឺសុត្ត គេយ្យ ។ល។

៧- ធម្មៈ ប្រែថា "ទេសនា" ដូចបទថា: ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ទេសនា-ចំពោះអ្នកទាំងឡាយ ។

៨- ធម្មៈ ប្រែថា "និស្សត្តនិជ្ជីវៈ គឺសភាវៈ មិនមែនជាសត្វ មិនមែនជាជីវិត" ដូចបទថា: តស្មិំ ខោ បន សមយេ ធម្មា ហោន្តិ សភាវៈដែលមិនមែនជាសត្វជាបុគ្គល មិនមែនជាជីវិត រមែងមានក្នុងសម័យនោះឯង ។

៩- ធម្មៈ ប្រែថា "ប្រក្រតី, ធម្មតា" ដូចបទថា: អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ សង្ខារទាំងឡាយមិនទៀង មានការកើតឡើងនិងសូន្យទៅជាប្រក្រតីឬជាធម្មតា ។

១០- ធម្មៈ ប្រែថា "វិការៈគឺរបស់ប្រែប្រួល" ដូចបទថា: ខយធម្មា សង្ខារា សង្ខារទាំងឡាយ មានការសាបសូន្យជាគ្រឿងប្រែប្រួល ។

១១ – ធម្មៈ ប្រែថា "គុណធម៌" ដូចបទថា: ន ហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ; ចត្តារោ ធម្មា វឌ្ឍន្តិ សភាវៈពីរយ៉ាងគឺគុណ ១ ទោស ១ ឲ្យផលមិនស្របគ្នាទេ; ពរ ៤ ប្រការ រមែងចំរើន ។

១២ – ធម្មៈ ប្រែថា "ការប្រព្រឹត្តមានសណ្តាប់ធ្នាប់ល្អ ឬ ឫកពា" ដូចបទថា: សីលវា កល្យាណធម្មោ បុគ្គលមានសីល មានសណ្តាប់ធ្នាប់ល្អ ។ សោតាបន្នោ អវិនិបាតធម្មោ សោតាបន្នបុគ្គលមានសណ្តាប់ធ្នាប់មិនធ្លាក់ចុះ ។ ពាលា ធម្មា បណ្ឌិតា ធម្មា ឫកពាជារបស់ជនពាល ជារបស់បណ្ឌិត ។

១៣ – ធម្មៈ ប្រែថា "សមាធិ" ដូចបទថា: ភាវិតធម្មោ កតសមណធម្មោ មានសមាធិចំរើនហើយ មានសមាធិបរិកម្មស្រេចហើយ ។

១៤ – ធម្មៈ ប្រែថា "បច្ចុប្បន្ន" ដូចបទថា: ធម្មដ្ឋិតតា ធម្មនិយាមតា ស្ថិតនៅឬកំណត់នៅក្នុងបច្ចុប្បន្ន ។ ទិដ្ឋធម្មិកោ អត្ថោ ប្រយោជន៍បច្ចុប្បន្ន ។

១៥ – ធម្មៈ ប្រែថា "ហេតុ ឬប្រវេណី" ដូចបទថា: ធម្មប្បដិសម្ភិទា ធម្មញ្ញុតា វៃឆ្លាយប្រាជ្ញក្នុងហេតុ ដឹងច្បាស់ហេតុ ។

ឋ.ស ធម្មោ សច្ចក្ខតោ ប្រែពាក្យនេះ ដាក់សេចក្ដីមានមកក្នុងពេល មុន ។

១៦- ធម្មៈ ប្រែថា "សាសនា" ថា "សេចក្ដីពិត" ដូចបទថាៈ ស្វាក្ខាតោ ធម្មោ សាសនាគឺថាគតសំដែងទុកល្អហើយ ។ អាទិកល្យាណោ ធម្មោ សាសនាមានលំអបទដើមឬពីរោះបទដើម ។ ញេយ្យោ ធម្មោ ញាតោ ធម្មោ សេចក្ដីពិតដែលគប្បីដឹង សេចក្ដីពិតដែលគប្បីដឹងហើយ ។ ធម្មានុធម្មប្បដិបន្នោ បុគ្គលប្រតិបត្តិតាមសេចក្ដីពិតសមគួរដល់សេចក្ដីពិត ។

១៧- ធម្មៈ ប្រែថា "បរមត្ថសច្ច" ថា "មគ្គផល-និព្វាន" ដូចបទថាៈ ទិដ្ឋធម្មោ បត្តធម្មោ បានឃើញបរមត្ថសច្ច បានលុះបរមត្ថសច្ច ។ អធិគតោ ខោ ធម្មោ មគ្គផល និព្វានគឺថាគតបានហើយ ។ ឧទាហរណ៍ ដែលសំដែងមកនេះជាសេចក្ដីបរមត្ថរបស់ពាក្យថាធម្មៈប៉ុណ្ណេះ ។

លំដាប់ពីនេះនឹងពោលអំពីវិគ្គហៈ របស់ធម្មៈ តទៅទៀត ធម្មសព្ទនេះមានវិគ្គហៈច្រើនយ៉ាង តែក្នុងទីនេះ នឹងស្រង់យកត្រឹម ៥ យ៉ាងៈ

១- ចតូសុ អបាយេសុ សំសារេ ច សត្តេ អបតមានេ ធារេតីតិ ធម្មោ សភាពគឺសេចក្ដីពិតឯណា រមែងទ្រទ្រង់នូវសត្វទាំងឡាយ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំង ៤ ឬក្នុងសំសារវដ្ដ សភាពនោះឈ្មោះថាធម្ម ។

២- សលក្ខណំ ធារេតីតិ ធម្មោ សភាពឯណាមែនទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួនគឺកុសលទាំង ៤ មានកាមាវចរកុសលជាដើម សភាពនោះឈ្មោះថាធម្ម ។

៣- ចាបកេ អកុសលេ ធម្មេ ធុនាតីតិ ធម្មោ សភាពឯណាមែនកំចាត់នូវអកុសលធម៌លាមកចេញ (តាមខន្ធសន្តាន) សភាពនោះឈ្មោះថាធម្ម ។

៤- សោតាបន្នាទីហិ អរិយេហិ ធារិយតីតិ ធម្មោ សភាពឯណាដែលព្រះអរិយទាំងឡាយ មានព្រះសោតាបន្នបុគ្គលជាដើម តែងទ្រទ្រង់ទុក (ទុកក្នុងសន្តាន) សភាពនោះឈ្មោះថាធម្ម ។

៥- យថានុសិដ្ឋំ បដិបជ្ជមានេ ចតូសុ អបាយេសុ អបតមានេ សត្តេ ការ្តា ធារេតីតិ ធម្មោ សភាពឯណាទ្រទ្រង់ញើនូវពួកសត្វដែលប្រតិបត្តិសមគួរដល់ពាក្យប្រៀនប្រដៅ មិនឲ្យធ្លាក់ទៅក្នុងអបាយទាំង ៤ សភាពនោះឈ្មោះថាធម្ម ។

អត្ថនិរុត្តិៈ របស់ធម្មៈ ដូចពោលមកនេះជាសេចក្ដីប្រែលម្រៀ ទៅតាមបែបហួសវិស័យសោតវិញ្ញាណរបស់អ្នកដែលមិនបានរៀន បែបផែនប្រែបាលី តែទុកជាយ៉ាងណាក៏គង់យល់សេចក្ដីខ្លះពុំខាន ។ ពាក្យថាធម្មៈឬធម៌មួយម៉ាត់នេះ បើទុកជាមិនមានបទគុណសព្ទ នឹកុសលឬអកុសលនៅផងកាន គង់យើងសង្កេតយល់បានតាមដំណើរសេចក្ដី ។

ធម្មសិក្សានេះគម្រោងនឹងនិយាយឲ្យច្បាស់ ប្រែស្រាយឲ្យចំមកជាពាក្យខ្មែរ យើងបាន ដំណើរនេះជាវិស័យរបស់អ្នករៀនវិធីប្រាជ្ញទើបអាចនឹងយល់បានដោយងាយ ប៉ុន្តែអ្នកដែលមិនបានរៀនរបៀបប្រាជ្ញក៏អាចទាន់ន័យកន្លែងសេចក្ដីនោះៗ បើគេពន្យល់ឲ្យយល់បាន ដូចយល់ថា នេះជាភាវេតព្វធម៌ (ធម៌គួរចំរើន) នេះជាបហាតព្វធម៌ (ធម៌គួរលះបង់) តែប៉ុណ្ណោះក៏អាចប្រព្រឹត្តប្រតិបត្តិតាមសាសនធម៌បាន ឬធម៌ដែលមានមកក្នុងពួកផ្សេងៗ យើងអាចសន្និដ្ឋានបានតាមភក្តិប្រចាំថា នេះជាធម៌ដ៏ល្អ នេះជាធម៌ដ៏លាមកដូចនេះជាដើម ។

សេចក្ដីរបស់ធម្មៈ តែប្រែមានក្នុងអត្ថនិងវិគ្គហៈ ដូចពោលមកនេះ សំដៅយកវត្ថុបរិយាដែលគួរប្រព្រឹត្តបានទាំងផ្លូវលោកផ្លូវធម៌ ឬសេចក្ដីល្អដែលជាច្បាប់ម្យ៉ាង សម្រាប់បន្ទុយកំឡាំងសេចក្ដីអាក្រក់របស់ពួកមនុស្ស ដើម្បីលើកកំឡាំងសេចក្ដីល្អឲ្យមានបរិបូណ៌ នឹងបានឈានទៅរកសេចក្ដីចំរើនឲ្យមានដំរៃ មានវេបផែនសណ្ដាប់ធ្នាប់ល្អប្លែកអំពីពួកសត្វតិរច្ឆាន ព្រោះជាការបរិភោគក្ដី ដេកក្ដី ភិតភ័យក្ដី រួមសំវាសនឹងមេថុនក្ដី ទាំង ៤ យ៉ាងនេះមានស្មើគ្នា ទាំងមនុស្សទាំងសត្វតិរច្ឆាន ទោះបើជាតិជាមនុស្សដោយសម្មតិហៅហារគេពិត តែបើគ្មានកល្យាណធម៌សម្រាប់ប្រតិបត្តិក្រៅពីនេះទៀតទេ ក៏មិនខុសអំពីកិរិយាសត្វតិរច្ឆានប៉ុន្មាន ធម៌នុងជាគ្រឿងក្រមសម្រាប់ប្រព្រឹត្តឲ្យសមស័ក្ដិជាមនុស្ស ឬថាធម៌នេះជា

សញ្ញាប័ត្រសម្រាប់មនុស្សក៏បាន ព្រោះថាមនុស្សយើងត្រូវតែតំកល់ខ្លួននៅក្នុងសីលធម៌ណាមួយ ទុកជាគោលដ៏សំខាន់សម្រាប់ត្រកូលរបស់ខ្លួនបើមិនច្រើនក៏តិច ដែលហៅថាត្រកូលមានធម៌ដើម្បីជាគម្រាប់ដល់បុគ្គលភាគគេរៀងទៅ ឯណាបើប្រាសចាកសីលធម៌ហើយមុខជានឹងរសាត់អណ្តែតទៅ ប្រទះប៉ះទង្គិចនឹងសេចក្តីទុក្ខលំបាក ដូចបកទឹងសំឡីដែលរសាត់អណ្តែតទៅតាមខ្យល់ ឬដូចរថយន្តនឹងនាវាដែលគ្មានបង្កិតគ្មានគ្រឿងទប់ មនុស្សដែលស្ថិតនៅក្នុងសីលធម៌ភ្ជាប់ខ្លួននោះ ដូចរថយន្តនឹងនាវាដែលមានបង្កិត មានយុត្តាសម្រាប់ទប់ ។

ពិតណាស់ ព្រះធម៌ដែលព្រះដ៏មានព្រះភាគបានសំដែងទុកហើយនោះជាច្បាប់ដ៏ល្អវិសេស សម្រាប់តម្រង់ដល់ប្រជាជនជាតិមនុស្សគ្រប់ជាន់ បើគេខំការសឲ្យប្រព្រឹត្តប្រតិបត្តិជឿតាម ដើម្បីឲ្យមានសណ្តាប់ធ្នាប់ល្អឈមមុខត្រង់ទៅរកសេចក្តីសុខក្សេមក្សាន្តចៀសចាកគ្រោះថ្នាក់ ទុក្ខភ័យតាំងអំពីលោកនេះ រហូតដល់លោកខាងមុខ ។

## អំពីប្រវត្តិនិងកិត្តិគុណរបស់ធម្មៈក្នុងពុទ្ធសាសនា

ធម្មៈគឺសេចក្តីពិតដែលចាប់កំណើតនៅក្នុងលោកជាធម្មតា ស្ថិតនៅជាចំនោះនៃសេចក្តីវិនាស ធម្មតាវត្ថុៗ ទាំងអស់ក្នុងលោក មានប្រាក់មាសជាដើមដែលបុគ្គលគាត់តែងសិប្បសូនធ្វើឡើង រមែងមានរូប

ប្រែប្រួលទៅផ្សេងៗ តាមកាលសម័យដែលនិយមកប់គាប់ ជួនកាលគេ ដែលមិនមែនជាប្រាក់មាសសុទ្ធទេ តែគេក្រឡៃធ្វើដោយក្លែងក្លាយឲ្យ មានពណ៌ដូចប្រាក់មាសសុទ្ធក៏បាន ប៉ុន្តែរបស់ក្រឡៃនោះមិនយូរប៉ុន្មាន ពិតប្រាកដដល់តែអ្នកពុជជនដែលគាប់ដឹងបាន ។ របស់នោះរមែងត្រឡប់ ទៅជារបស់ថោកទាបឥតថ្លៃ នាំឲ្យខូចសេចក្ដីប្រាថ្នារបស់អ្នកត្រូវការទុក ទៅ ក្នុងទីបំផុតរបស់ដែលបន្លំនោះប្រែទៅជាវត្ថុប្រើប្រាស់ពុំកើត សេចក្ដី នេះយ៉ាងណាមិញ ក្បួនគម្រោងច្បាប់ទម្លាប់ ក្នុងលទ្ធិណាមួយ ដែល គេហៅថាធម៌ ដោយសេចក្ដីសន្មតរបស់គេដែលគាត់តែងឡើងដោយ ឧបាយមិនសមហេតុផល គឺជាដំណើរមិនពិត, ក្បួនច្បាប់ទាំងនោះ គង់ ត្រូវអ្នកផងដែលមានប្រាជ្ញាល្អ យល់តាមប្រាប់សេចក្ដីខុសបាន ថា ជាលទ្ធិមិនពិត បើជាមិនមានអ្នកណាចាប់ជាក់បានភ្លាមៗ ក៏គង់គេដឹង បាន ឬគេកន្លងកាលក្នុងកាលដែលឲ្យផលមិនសក្តិសិទ្ធិ លទ្ធិនោះក៏ ទៅជារបស់វៀរពេយ សាបរលាប លែងមានអ្នកណាចុះចូលត្រូវការ ប្រតិបត្តិជឿតាមក៏យ៉ាងនោះដែរ ។ ចំណែកខាងធម្មៈ គឺសេចក្ដីពិតជា សកាលមានអាយុជីវិតរស់នៅក្នុងលោក មិនចេះរៀវរោយថយចុះដូច្នោះ ឡើយ ។

ស្វាក្ខាតធម៌ ដែលព្រះសម្មាសម្ពុទ្ធរបស់យើង ទ្រង់បានត្រាស់ ដឹងឡើងហើយ ទ្រង់ប្រកាសប្រដៅប្រជាជនក្នុងលោក តាំងដើមដំបូង

មិនសូវមានមនុស្សជ្រះថ្លាជឿកាន់ច្រើនប៉ុន្មាន លុះដល់កាលខាងក្រោយមក ទើបពួកទេវតានិងមនុស្សបានដឹងឮសុះសាយច្រើនគ្នាស្ញើចសរសើរថា ធម៌នេះជាធម៌ពិត ប្រព្រឹត្តទៅដើម្បីសេចក្ដីសុខក្សេមក្សាន្ត រួបនាំគ្នាប្រតិបត្តិតាម រហូតបានសម្រេចផលនិព្វានតាមនិស្ស័យរៀងខ្លួន យ៉ាងសក្តិសិទ្ធិដូចពិតស្រាប់ហើយតើង ៗ ដូច្នេះ គឺសេចក្ដីពិត ៤ នេះអាយុជីវិតដ៏មាំមួន ជារបស់មិនចេះចាស់មិនចេះស្លាប់ អាចរស់នៅតាំងមានដំខ្សែអង្វែងតទៅមិនចេះចុះថយឡើយ សេចក្ដីនេះគប្បីសន្និដ្ឋានបានដោយងាយ ដូចយ៉ាងព្រះធម៌របស់ព្រះសម្ពុទ្ធនៃយើងទាំងឡាយ ដែលព្រះអង្គសំដែងឡើងតាមពិត មិនវិបរិតខុសចាកសេចក្ដីពិត បើយើងគិតតាំងអំពីឆ្នាំដែលព្រះអង្គបរិនិព្វានមកដល់ឥឡូវនេះបាន ២៤៨៩ ឆ្នាំហើយ ទោះបីយូរអង្វែងមកប៉ុណ្ណោះ ព្រះធម៌នោះក៏នៅថ្មីទៀងទាត់ដដែលដូចប្រក្រតី ឥតមានចាស់គ្រាំគ្រា ប្រែប្រួល ខូចខ្សែយ៉ាងណាៗឡើយ សមដូចពុទ្ធភាសិតថា:

ជីរន្តិ វេ រាជរថា សុចិត្តា អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ សន្តោ ហវេ សព្ភិ បវេទយន្តិ

សេចក្ដីថា រាជរថទាំងឡាយ ដែលនាយជាងរចនាល្អហើយ រមែងចាស់គ្រាំគ្រាទៅពុំខាន មិនត្រឹមតែរថទាំងឡាយប៉ុណ្ណោះឡើយ ទោះទាំងសរីរៈកាយ (របស់សត្វទាំងឡាយ) ក៏គង់ដល់នូវសេចក្ដី

ចាស់ទ្រុឌទ្រោមដូច្នោះដែរ មានតែធម៌របស់ពួកសប្បុរសទើបមិនដល់នូវសេចក្តីចាស់ទ្រុឌទ្រោម ពួកសប្បុរសតែងប្រាប់ជាមួយនឹងពួកសប្បុរសផងគ្នា ហេតុនេះឯង ៗ ពុទ្ធភាសិតដូចពោលមកនេះជាគ្រឿងគាំទ ដើម្បីបញ្ជាក់ពាក្យថាធម៌ឲ្យឃើញពិត ថាជាសភាពមិនចេះចាស់ទ្រុឌទ្រោម ផងក៏ប្រែមិនមានសេចក្តីចាស់ទេ សេចក្តីឈឺចាប់ក៏មិនមាន កាលបើមិនមានសេចក្តីឈឺចាប់ទេ សេចក្តីស្លាប់ក៏មិនមាន ៗ ពាក្យថាធម្មៈដែលអធិប្បាយមកនេះសំដៅយកសេចក្តីពិត ដែលសំដែងអំពីសេចក្តីពួអត្រក់ ជាសភាពឥតរូប មានតែនាមៗដែលចាប់កំណើតនៅក្នុងលោក សម្រាប់ដឹងបានហើយបញ្ចប់ក្នុងប៉ុណ្ណោះ ឥតមានអ្នកណាស្រាវជ្រាវរកប្រត្តិឲ្យឃើញថាធម៌នេះចាប់កំណើតពីកាលណាៗបានឡើយ ដូចក្នុងទិនវ្យល់ដែលៈគមិនគាប់ដឹងដើមកំណើតបានដូច្នោះដែរ គឺជាធម្មជាតិតែងកើតមាននៅក្នុងលោកជាធម្មតា ៗ

សេចក្តីខាងលើនេះ ល្មមយល់បានថា អំពើល្អគ្រប់ជារបស់បុគ្គលរស់នៅពាស់ពេញលោក ចាំឯមគ្គផលនិព្វាន ក៏មាននៅប្រាកដមិនត្រូវវិនាសបាត់បង់ចាកលោកដោយអន្តរាយណាមួយ សូម្បីរៀងក្នុងចាំនមូលត្រូវក្ដីងនេះ អំពើនិងមគ្គផលនិព្វានគាប់គាំនៅដដែល ទោះបីនរណាក៏លុបលាងចេញពុំបាន បំណែកខាងពាក្យថែកពោកថា ធម្មបីធម៌ចាស់ ទោះនឹងចុះគ្នានបួលមកយ៉ាងណាក៏ដែងគឺសេចក្តី

ពិតមិនបានឡើយ ។ បុណ្យគឺអំពើល្អ បាបគឺអំពើអាក្រក់ គុណគឺសេចក្តីចំរើន ទោសគឺសេចក្តីវិនាស ទាំង ៤ យ៉ាងនេះជាដើម ឈ្មោះថាវត្ថុគឺសំណើផ្លូវការរបស់ធម៌ ដែលជាសេចក្តីពិតមាននៅប្រចាំលោក សូម្បីក្នុងកាលធម៌ទាំងពួងបាំងស្ងាត់ គឺកាលដែលមិនមានព្រះពុទ្ធត្រាស់ឡើង ឬមិនមានអ្នកប្រាជ្ញណាយកនូវបុណ្យ បាប គុណ ទោស បកស្រាយនៅជាប្រាកដឥតមានសាបរលាបលាក់បាត់ទេ ទាំងប្រជាជនក្នុងលោកក៏មិនដែលពោលនិយាយថា វត្ថុនេះបុណ្យ បាប គុណ ទោស ចាស់ទ្រុឌទ្រោមណាស់ ឈឺធ្ងន់ជាពន់ណាស់ ឬថា ស្លាប់បាត់ទៅហើយដូច្នេះឡើយ ពាក្យដែលគេនិយាយរៀងរហូតថា ធម៌ថ្មី ធម៌ចាស់នោះ ត្រឡប់ទៅជាឥតប្រយោជន៍ទេ ។ បើបុគ្គលប្រុសស្រីឯណាក្នុងលោក មានឆន្ទៈយកចិត្ត ប្រព្រឹត្តល្អត្រូវតាមសីលធម៌ មានព្រហ្មវិហារផ្សាយទៅក្នុងពួកសត្វ មានកតញ្ញូកតវេទី ចំពោះលោកអ្នកមានគុណគឺមាតាបិតាជាដើម បុគ្គលនោះក៏រមែងបានបុណ្យឬប្រទះសេចក្តីចំរើន បើជាមានឆន្ទៈយកចិត្ត ប្រព្រឹត្តអាក្រក់ខុសចាកសីលធម៌មិនមានព្រហ្មវិហារផ្សាយទៅក្នុងពួកសត្វ មិនមានកតញ្ញូកតវេទីចំពោះលោកអ្នកមានគុណទេ ក៏រមែងបានបាប ទទួលទោសដោយខ្លួនឯង មិនចាំបាច់មាននរណាប្រគល់បុណ្យប្រគល់បាបឲ្យទេ នេះជាសេចក្តីសំដែងឲ្យឃើញថា បុណ្យបាបមិនចេះវិនាស អ្នកណាធ្វើកម្មណា អ្នកនោះត្រូវបានក្នុង

ការលោះបង់កាលខាងមុខៗ ។ បុណ្យបាបគុណទោសទាំងនេះឯងហៅថា ធម៌; មួយទៀតគួរគប្បីត្រូវថា ខាងខុទ្ទកនិកាយ មានសេចក្តីថា ពួកធម៌ ជាកុសល ហៅថាសគ្គធម៌ គឺជាផ្លូវដ៏ពិតមួយយ៉ាងសម្រាប់នាំមកនូវសុខ សួស្តី នាំមកនូវសេចក្តីចំរើន ដល់បុគ្គលអ្នកប្រព្រឹត្តសុចរិត; ពួកអកុសល ហៅថាបរធម៌គឺជាផ្លូវពិតតែមួយខ្សែ សម្រាប់នាំមកនូវទុក្ខ នាំមកនូវ សេចក្តីវិនាសរបស់បុគ្គលអ្នកប្រព្រឹត្តទុច្ចរិត ចំណែកខាងពួកកុសលធម៌ មានសីល សមាធិ បញ្ញា ជាដើមដែលធ្វើប្រយោជន៍ឲ្យដល់ខ្លួនដូចជា មាតាបិតាធ្វើប្រយោជន៍ដល់បុត្រធីតា ព្រោះហេតុនោះទើបលោកហៅថា សគ្គធម៌; ពួកអកុសលធម៌ មានលោភៈ ទោសៈ មោហៈ ជាដើម ដែល-នាំបណ្តាលធ្វើប្រយោជន៍ឲ្យវិនាស ដូចជាបច្ចាមិត្ត ជាសឹកសត្រូវមក ពីខាងក្រៅ មកធ្វើឲ្យខូចប្រយោជន៍ ព្រោះហេតុនោះទើបលោកហៅ ជាបរធម៌ ។

បុណ្យ បាប គុណ ទោស សគ្គធម៌ បរធម៌ ដូចសំដែងមកនេះ ឈ្មោះថាប្រវត្តិរបស់ធម៌ ដែលជាដើមឫសតាមកំណើតកើតឯងហើយតាំង ឫសជាប់នៅទៀតតាំងជាធម្មតា មិនចេះរលាស់ក្រាំក្រា ឬវិនាសសាបសូន្យ ទៅណាពិត តែជារបស់ស្ថាក់កប់ផុតផាត់ក្នុងបញ្ញារបស់បុថុជ្ជន ដូចភ្លើងជា របស់មាននៅទៀតតាក់តែងជាប់កំណើតជាប់នៅនឹងកាលឥស ឬនៅក្នុង ដើមឈើ កាលបើគេរាវរកផ្ទះត្រៀនផ្លុំ ត្រូវតាមហេតុផលល្អ ភ្លើងក៏

ដេះលះជាតណ្ហាតឡើង បើមិនបេះគ្រឿងផ្សំទេ ភ្លើងមិនអាចឆេះឡើងជាថ្មី មួយទៀតគេសង្កេតថាភ្លើងដែលកើតអំពីជាតិឈើ ឬអំពីធាតុអ្វីផ្សេងៗ គឺជារបស់ស្ថិតនៅមាននៅជាធម្មតា មិនចេះវិនាស, គ្រូពេទ្យអ្នកចេះចាំក្បួនតម្រាវែងផ្សំធាតុប្តូរអាតូមផ្សេងៗ ឲ្យទៅជាភ្លើងកែកេតបានដោយងាយ ពាក្យដែលយើងធ្លាប់និយាយថា ភ្លើងរលត់ នេះជាសេចក្តីសន្មតិនៃភ្លើងគ្រាន់តែរលត់បាត់អំពីចក្ខុវិញ្ញាណប៉ុណ្ណោះ ឯងជារលត់បាត់ទៅពីលោកមែនតែនកក៏ទេ សេចក្តីនេះយ៉ាងណាមិញ ដំណើរនិងកិច្ច-គុណព្រះធម៌ជាសភាពដែលពិតប្រាកដរមែងមាននៅដោយខ្លួនឯង មិនចេះប្រែប្រួលវិនាសសាបសូន្យ មិនចេះស្លាប់ក៏យ៉ាងនោះដែរ ។ ពាក្យដែលយើងនិយាយថាព្រះធម៌សាបសូន្យ ឬថាសាសនារៀវកេយ នេះជាសម្មតិវោហារគ្រាន់តែជាពាក្យសម្រាប់ប្រើហៅបណ្តោះអាសន្ន ឬពាក្យថា សាបសូន្យរៀវកេយនោះគ្រាន់តែសំដៅយកថាព្រះធម៌សាបសូន្យចាកខន្ធសន្តានរបស់បុគ្គលអ្នកសិក្សារៀនសូត្រប្រតិបត្តិប៉ុណ្ណោះ ។ មគ្គផលនិព្វានឈ្មោះថាកិត្តិគុណរបស់ធម៌ តែងផ្សព្វផ្សាយនៅក្នុងលោកដោយហូរហែជាដរាបមកមិនដាច់ ព្រោះហេតុនោះបុគ្គលអ្នកស៊ើបដំណើរតេធម៌ក្នុងលោកនេះ តែងមានតែកាលៗកាល តាមសេចក្តីប្រតិបត្តិក្នុងសាសនារបស់គេ ប៉ុន្តែប្រែនតែប្រែះទៅលើផ្លូវវង្វេង ដោយអំណាចអវិជ្ជានាំសត្វឲ្យវង្វេង ឬដោយគំនិតយល់ខុសតាមលទ្ធិរបស់គ្រូដោយ

ម្ដង ៗ ក្នុងកាលជាបន្ទោះព្រះពុទ្ធត្រាស់ឡើងនូវប្រាជ្ញាថា ខាងបុគ្គល
ខ្លះក្នុងលោកមានចិត្តទៀយណាយទាកកាមគុណ នឹកគួតបង់ស្ទះស្វែងរក
ប្រវត្តិពង្សាវតារ ដែលជាក្រសែនៃមោក្ខធម៌គឺព្រះនិព្វាន ហើយលះគេ
គ្រហាស្ថបេញចាកលោមារម្មណ៍ កាន់ភេទជាតាបសឥសីប្រព្រឹត្តតបវត្ត
ដើម្បីស្វែងរកព្រះនិព្វានជាធម្មតា ៗ តាបសខ្លះប្រឹងប្រែងបានតែត្រឹម
ឈានសមាបត្តិ ឬអភិញ្ញាជាលោកិយប៉ុណ្ណោះ តាបសខ្លះឃ្លាតវង្វេង
ដោយមោហខ្លះគ្រឿងជ្រុះ ឬមានគ្រឿងជ្រុះជាគុណវិជ្ជាប្រាជ្ញាស្មារតីមិនទាន់
គ្រប់គ្រាន់; ព្រះសម្ពុទ្ធរបស់យើង កាលនៅជាពោធិសត្វ ក៏នៅក្នុងពួក
តាបសដូច្នោះដែរ ព្រះអង្គតែងជាប់ព្រះហឫទ័យក្នុងការស្វែងរកព្រះធម៌
ពោះបីព្រះអង្គបានជាក្សត្រិយ៍សោយរាជ្យ ដែលគួរស្រវឹងក្នុងសម្បត្តិ
និងយសបរិវារ ទ្រង់ក៏មិនភ្លេចអំពីដំណើរបុណ្យបាប តែងពេញព្រះ
ហឫទ័យក្នុងភេទតាបសជារឿយ ៗ ទ្រង់ប្រព្រឹត្តវត្តយ៉ាងក្រៃជាងតាបស
ឯទៀត ៗ ជាដរាបអស់ច្រើនជាតិណាស់ ៗ ព្រះមហាបុរសមានព្យាយាម
ក្លៀវក្លា អន្ទោលអន្ទាលមិនតក់មិនរៃលែងពោលអំពីការស្វែងរកមោក្ខធម៌
ព្រោះតែស្រវាំការដឹងថាមុខជាទីពឹងដូចប្រាជ្ញា ព្រះអង្គទ្រង់ប្រឹងសន្សំ
សេចក្តីល្អលះសេចក្តីអាក្រក់ ចំណាំប្រវត្តិរបស់ព្រះអង្គនិងព្រះធម៌ដែល
ព្រះអង្គធ្លាប់ប្រតិបត្តិមករៀងរាបដរាបដល់បច្ចិមជាតិ ទើបបានគ្រឿង
ផ្សំគាត់សព្វគ្រប់ដែលហៅថាបារមីធម៌ ១០ ប្រការនោះឯង ៗ

លុះព្រះបរមពោធិសត្វបានបារមីធម៌ មូលមកគ្រប់គ្រាន់ ក៏បានរំពឹងស្រាវជ្រាវរកពន្លករការព្រះធម៌ជាអនុលោមបដិលោម បានឃើញជាក់ច្បាស់ដោយសព្វញ្ញុតញ្ញាណ ហើយទ្រង់សំដែងបើកបង្ហើបបង្ហាញធម៌នោះៗដល់ពួកពុទ្ធបរិស័ទឲ្យភ្លឺច្បាស់ជាក់ដូចជា ព្រះចន្ទរះឡើងក្នុងថ្ងៃ ១៥ កើត ។ ព្រះធម៌ដែលជាប់កំណើតនៅក្នុងផ្ទៃលោកជាតុជាយូរលង់មកហើយនោះស្រាប់តែផុះផុលឡើង ហាក់ដូចជាប្រសូតចាកលោកជាតុមកប្រតិស្ឋានថ្មីៗចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគ នេះឯងហៅថាព្រះអង្គត្រាស់ដឹង ។ មូលហេតុដែលនាំឲ្យពួកតាបសឯទៀតៗក្តី តាមសតិព្រះពោធិសត្វក្តី ខំសង្កត់បំពេញបារមីធម៌ទាំងនោះ ក៏ព្រោះអស្រ័យការដឹងគុណក្រអូប ការចាំប្រវត្តិនិងគតិគុណរបស់ធម្មៈជាប់ហោៗមក ដូចដំណើរជាមាសពេជ្រជាបច្ច័យ នាំឲ្យគេស្វែងរកមាសពេជ្រនឹងអស្រ័យការដឹងជាដើមហេតុ ទើបមានការស្វែងរកជាខាងនេះត្រាយគោ មកហេតុតាល់តែបានដូចប្រាថ្នា ។ ដំណើរជាមគ្គផលជានិព្វានក៏រមែងមានគុណត្រអូបជាប់នៅក្នុងលោក សូម្បីមគ្គផលជាធម៌នាំសត្វឲ្យរួចឡើងចាកលោក ព្រះនិព្វានជាគុណជាតិផុតស្រឡះចាកលោកហើយក៏ពិតមែន តែកិត្តិស័ព្ទរមែងស្ថិតនៅក្នុងលោកមិនបេះសាបសូន្យ ។ លុះព្រះអង្គបរិបូណ៌ដោយប្រាជ្ញាស្មារតី គ្រប់គ្រាន់ដោយសេចក្តីត្រិះប្រាជ្ញាច្បាស់ចំពោះព្រះអង្គហើយ ទើបទ្រង់លើកស្រង់ ស្រាវជ្រាវប្រមូល

យក ព្រះធម៌ដែលមាននៅក្នុងលោកស្រាប់នោះមកសំដែងសើរើបែក រលែកឲ្យមានមេមាតិកាដោយគ្រងគម្រៀប ឲ្យមានក្រមងមានរបៀបជា គោលតារែកកក់ក្រៅ សង្ខេបពិស្ដារច្បាស់លាស់ជាក់ស្ដែងឡើងដើម្បីឲ្យ ពួកបរិស័ទនិកាយរបស់ព្រះអង្គ ងាយស្ដាប់ងាយពិចារណារកផ្លូវប្រតិបត្តិ ពួកប្រជាជនអ្នកមានសេចក្ដីជ្រះថ្លាក្នុងធម៌ គោរពចំពោះព្រះអង្គក៏នាំគ្នា ហៅថាព្រះអង្គបានត្រាស់ ដកបមក ។ ធម៌ដែលព្រះអង្គបានត្រាស់ រឿងតាំងនោះ ក៏គឺធម៌ដែលធ្លាប់មានស្រាប់នៅក្នុងលោកនោះឯង ។ ព្រះបរមសាស្ដាចារ្យ បានត្រាស់ដឹងធម៌ឡើងក្នុងលោកក្នុងកាលណា ម្ដង ៗ គួរហៅថាអគ្គសង្គាយនាមួយលើកហើយ ក្នុងកាលនោះរាប់ជា សង្គាយនាមុនដំបូងបង្អស់ ជាគុណដ៏ប្រសើរបំផុតជាងបណ្ដាប់ជាងសង្គាយ-នារបស់ព្រះអរហន្តទាំងឡាយ ដែលធ្វើក្នុងកាលជាខាងក្រោយ ។

ពណ៌នាមកអំពីភក្តិគរិត្តហ; របស់ធម្ម:

- ព្រមទាំងប្រវត្តិនិងកិត្តិគុណរបស់ធម្មៈចប់តែប៉ុណ្ណេះ ។